Nº 7
N-69-3-53
Tossteaknea vaddey
INDOCHINE FRANÇAISE RÉGIE

# ព្រះរាជាណាចក្រកម្ពុជា

## មន្ទីរស្តីការក្រសួងសិក្សាធិការ

# ទស្សនាវដ្តី

សម្រាប់

# គ្រូបង្រៀន

ឆ្នាំទី ៤ លេខ ៧

ខែមិនា ព.ស. ២៤៩៥

ឆ្នាំសិក្សា ១៩៥២-១៩៥៣

# ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

ទស្សនាវដ្ដី សំរាប់គ្រូបង្រៀន

## បញ្ជីរឿង


| | | |
|---|---|---|
| | | ទំព័រ |
| សេចក្ដីណែនាំ | | ៣ |
| ឧត្ដមដ្ឋាន និង មធ្យមដ្ឋានទី ២ | ភាសា | ១០ |
| មធ្យមដ្ឋានទី ១ | ភាសា | ១៨ |
| អាទិកដ្ឋាន | ភាសា | ២១ |
| បវិច្ចណដ្ឋាន | ភាសា | ៣៣ |
| កុមារដ្ឋាន | ភាសា | ៣៨ |
| តែងសេចក្ដីសម្រាប់ប្រថមភូមិបំពេញវិជ្ជា | | ៤២ |
| តែងសេចក្ដីសម្រាប់ប្រថមភូមិជាន់ដំបូង | | ៤៥ |
| កុមារដ្ឋាន - នព្វន្ត រង្វាស់រង្វាល់ | | ៤៩ |
| បវិច្ចណដ្ឋាន – នព្វន្ត - រង្វាស់រង្វាល់ | | ៥៤ |
| អាទិកដ្ឋាន – នព្វន្ត – រង្វាស់រង្វាល់ | | ៥៨ |
| អាទិកដ្ឋាន – វត្ថុស្វាធ្យាយន៍ – វិធីបង្ការរោគ | | ៦៤ |
| បវិច្ចណដ្ឋាន – វត្ថុស្វាធ្យាយន៍ – វិធីបង្ការរោគ | | ៧០ |
| កុមារដ្ឋាន – វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ | | ៧៥ |
| លោកទីតិ (គ្រប់ថ្នាក់) | | ៧៨ |
| មេសូត្រ រត់មាត់ | | ៨០ |

# សេចក្ដីណែនាំ

## អំពីបង្រៀននព្វន្ត និងរង្វាស់រង្វាល់

គ្រូបង្រៀនសិស្សឲ្យចេះរាប់ ចេះគិតរកចំនួនមាត់ទទេ ឬសរសេរ ឲ្យចេះវាស់ចេះវាល់ ចេះថ្លឹង ចេះស្មានប្រវែង ទំហំ ហើយនឹងទម្ងន់របស់ផ្សេងៗផង ការសិក្សាដូច្នេះមានប្រយោជន៍សំខាន់ណាស់ ។

### អំពីនព្វន្ត

### អំពីបង្រៀនគិតរកចំនួននឹងក្បាល

បង្រៀនគិតរកចំនួននឹងក្បាលមានប្រយោជន៍ឲ្យក្មេងចេះគិតរកចំនួននោះឃើញមួយរំពេច យូរទៅក្មេងនឹងចេះគិតរកចំនួនអ្វីៗក្នុងការរកស៊ីលក់ដូរមិនចាំបាច់មានដីសនឹងក្ដារខ្មៀនទេ ទើបគិតរកចំនួននោះឃើញ ។ ការបង្ហាត់ក្មេងឲ្យចេះគិតរកចំនួននឹងក្បាលនេះ នាំឲ្យក្មេងមានប្រាជ្ញាឆ្លាតវៃបង្ខំឲ្យចេះគិតពិចារណា នាំឲ្យចាំចំនួន នាំឲ្យបង់រៀនកុំឲ្យចាញ់គេ ម្យ៉ាងទៀតការហាត់នេះ នាំឲ្យរៀនបានពេះភាយសប្បាយហើយមិនស្ទាត់ផង ជាហេតុនាំឲ្យមានរបបល្អៗ កាលណាកូនសិស្សរាប់របស់គិតចំនួនរួចហើយត្រូវសួរឲ្យគិតរកចំនួននឹងក្បាល ឲ្យគិតពីចំនួនដែលមានរបស់ជាទី

តាំងរៀនទៅដល់ចំនួនដែលគ្មានរបស់កាច់ ត្រូវបង្ហាត់តាមរបៀបឡាម៉ារទីនីញេរ មានគ្រូខ្លះប្រឡំការគិតរកចំនួននឹងក្បាល នឹង ការគិតរកចំនួនដោយមាត់ទទេ ។ ការបង្រៀនគិតរកចំនួនដោយមាត់ទទេ គឺដូចជាឲ្យរាប់ពីរ ៗ បី ៗ បួន ៗ ប្រាំ ៗ ត្រូវធ្វើមុនការហាត់សរសេរ ការបង្រៀននេះត្រូវឲ្យតិចពេលផង (១០មីនុត) ឯការហាត់គិតរកចំនួននឹងក្បាល ត្រូវធ្វើមុនឲ្យកូនសិស្សរកចំណោទ ។

## អំពីបង្រៀនគិតរកចំនួននឹងក្បាលតាមរបៀបឡាម៉ារទីនីញេរ

កូនសិស្សម្នាក់ ៗ មានក្ដារឆ្នួនមួយដីសមួយដុំគ្រប់គ្នា លោកគ្រូចោទសួរអ្វីទៅកូនសិស្សត្រូវគិតនឹងក្បាល កាលណាលោកគ្រូគោះតុម្ដងកូនសិស្សត្រូវសរសេរចំនួនដែលគិតឃើញនោះនៅក្ដារឆ្នួន ធ្វើលេខឲ្យធំ ៗ ហើយច្បាស់ផង លុះលោកគ្រូគោះតុម្ដងទៀត កូនសិស្សត្រូវលើកក្ដារឆ្នួនឡើងបង្ហាញចំនួនដែលគិតឃើញនោះទៅលោកគ្រូ ៗ មើលភ្លាមហើយប្រាប់ថា នេះខុសនោះត្រូវ ហើយសរសើរកូនសិស្សណាដែលធ្វើត្រូវ រួចបង្គាប់កូនសិស្សណាដែលធ្វើខុសឲ្យកែភ្លាមឡើង ហើយបង្គាប់ឲ្យដាក់ក្ដារឆ្នួនចុះវិញ ជួនណាកូនសិស្សលបមើលចំនួនដែលត្រូវឆ្លើយ ទៅគេដ៏ជិតខាងវា ហើយសរសេរចំនួននោះតាមគេ ដើម្បីនឹងបំបាត់សេចក្ដីនេះត្រូវធ្វើ

ដូច្នេះ លោកគ្រូឲ្យកូនសិស្សរាប់លេខចំណាំខ្លួនទៅតាមជួរអង្គុយ ១.២.៣ ៤.៥.៦.៧.៨.៩.១០ ។ល។ ហើយលោកគ្រូចោទសួរពីរយ៉ាង មួយយ៉ាងត្រូវឲ្យកូនសិស្សមានលេខគត់ចំណាំខ្លួន គឺ២ ៤.៦.៨.១០ គិតរកចំនួនឆ្លើយ មួយយ៉ាងទៀតត្រូវឲ្យកូនសិស្សដែលមានលេខសេសចំណាំខ្លួន គឺ១.៣ ៥.៧.៩ គិតរកចំនួនឆ្លើយ ធ្វើដូច្នេះទើបមើលគ្នាមិនបានទេ លោកគ្រូនឹងចំណាំបានថា កូនសិស្សណាមានប្រាជ្ញាឆ្លាត កូនសិស្សណាធ្វេសប្រហែស ហើយលោកគ្រូនឹងបង្ខំកូនសិស្សខ្ជិលនោះឲ្យរៀនច្រើនឡើងឲ្យបានទាន់គេ ។

ចំណោទ

## អំពីរើសចំណោទឲ្យកូនសិស្សធ្វើ

ក) តែងចំណោទត្រូវឲ្យប្រកបនឹងការដែលបានបង្រៀនរួចហើយ កុំនឹងពួនក្ដី កុំវង្វាស់វង្វាល់ក្ដី ។

១)– ចំណោទត្រូវឲ្យល្មមនឹងចំណេះកូនសិស្ស គឺឲ្យមានសេចក្ដីពិបាក តិចៗឡើង ប្រយោជន៍ឲ្យគេរំពឹងរិះគិត ធ្វើឲ្យបានឆាប់ ហើយត្រូវផង ប៉ុន្តែសូមលោកគ្រូចាំថា ត្រូវធ្វើពីងាយទៅពិបាកជាដំរាប ។

១– ត្រូវតែងចំណោទក្នុងការដែលទើបនឹងបង្រៀនថ្មីៗ

២– សេចក្ដីចោទត្រូវឲ្យងាយហើយច្បាស់ផង

៣ - ក្នុងចំណោទត្រូវមានចំនួនដែលជាប្រាកដ (គឺថ្លៃរបស់ឬចំនួនអ្វីៗ ដែលមានប្រាកដពិតក្នុងវេលាឥឡូវនេះ) លោកគ្រូត្រូវមានសៀវភៅមួយផ្សេងសំរាប់កត់ចំណោទដែលលោកគ្រូបានពិនិត្យយល់ឃើញត្រូវតាមពេលតាមសេចក្ដី ហើយបានឲ្យកូនសិស្សធ្វើផង សេចក្ដីចំណោទនេះត្រូវកែប្រែថែមថយចំនួនឬថ្លៃតាមសម័យកាលឆ្នាំទៅ ៗ

## អំពីបង្រៀនគិតរកចំណោទ

នៅថ្នាក់កុមារដ្ឋាន នឹងបវិច្ឆណដ្ឋាន ត្រូវឲ្យកូនសិស្សមើលសេចក្ដីចំណោទនោះបួនប្រាំនាក់ រួចលោកគ្រូពន្យល់សិស្សឲ្យយល់នាំសេចក្ដីឧបមាឲ្យឃើញងាយ ធ្វើគំនូសដួសចំនួននៅក្ដារខៀនបញ្ជរ រួចឲ្យកូនសិស្សធ្វើជាអ្នកលក់ ជាអ្នកទិញ (បើនិយាយពីលក់របស់) បើចំនួនក្នុងចំណោទនោះច្រើនត្រូវ ឧបមាមកជាចំនួនតិចវិញប្រយោជន៍ឲ្យគិតឃើញឆាប់ សួរបញ្ជាក់កូនសិស្សឲ្យវាយល់ប្រាកដ លុះឃើញថាកូនសិស្សយល់ច្បាស់ហើយទើបឲ្យវាធ្វើទៅ ៗ

នៅថ្នាក់អាទិកដ្ឋាន  កាលណាកូនសិស្សមើលសេចក្ដីចំណោទរួច ហើយ ត្រូវសួរឲ្យឆ្លើយអំពីសេចក្ដីចំណោទនោះថាក្នុងចំណោទនេះគេសួរ ពីអ្វី សួរអ្វីជាមុន អ្វីជាបន្ទាប់ អ្វីជាក្រោយ ៗ ល ៗ ត្រូវធ្វើដូចម្ដេចឲ្យឃើញ ចម្លើយនេះ  ចុះចម្លើយនោះ  ៗ ល ៗ  បើកូនសិស្សមិនដឹងច្បាស់សូម លោកគ្រូរំលឹកពីចំណោទជាគំរូដែលលោកគ្រូបានពន្យល់ បានឲ្យវាធ្វើរួច ហើយនោះផង ហើយសួរបញ្ជាក់កូនសិស្សឲ្យវាយល់ប្រាកដ ទើបឲ្យវា ធ្វើទៅ ។

## អំពីកែចំណោទ

វេលាដែលកូនសិស្សធ្វើចំណោទ  លោកគ្រូត្រូវដើរក្រោយខ្នងវា ពិនិត្យមើលហើយសំគាល់ថា កូនសិស្សនេះធ្វើត្រូវ កូនសិស្សនោះភាន់ច្រឡំ ក្នុងការរកចម្លើយ កូនសិស្សនោះធ្វេសប្រហែសក្នុងរបៀបឆ្លើយ កូនសិស្សនោះទៀតភាន់ច្រឡំក្នុងគិតលេខ ។

ត្រូវកែចំណោទកូនសិស្សព្រមគ្នាទាំងអស់  នៅក្ដារខៀនបញ្ជរ លោកគ្រូ ត្រូវឲ្យកូនសិស្ស ដាក់របៀបហូរហែនៅក្ដារខៀនបញ្ជរនោះ ហើយរំលឹកកូនសិស្សណាដែលមានភាន់ច្រឡំឲ្យបានយល់ឡើង រួចឲ្យ កែនៅសៀវភៅឡើង ។ លោកគ្រូត្រូវដើរក្រោយខ្នងកូនសិស្សគ្រប់គ្នា ហើយដាក់ពិន្ទុនៅសៀវភៅសរសេរវាមួយរំពេច ។

# អំពីរង្វាស់រង្វាល់

មានគ្រូខ្លះសំគាល់ជាក់ច្បាស់ថា កូនសិស្សចេះក្បួនរង្វាស់រង្វាល់ ហើយកាលណាឃើញកូនសិស្សនោះរាប់ស្ទាត់ ចំណែកធំនឹងចំណែកតូច ជាម៉ែត្រ លីត្រ ក្រាម ។ល។ ហើយនឹងចេះផ្លាស់ចំនួនពីចំណែកធំទៅចំណែកតូចពីចំណែកតូចទៅចំណែកធំវិញ ប៉ុន្តែបើគេឲ្យកូនសិស្សនោះវាស់ឬវាល់ឬថ្លឹងរបស់អ្វី ៗ ស្រាប់តែឃើញក្មេងនោះមិនចេះទាំងកាន់ម៉ែត្រ មិនចេះទាំងប្រើលីត្រ មិនទាំងស្គាល់កូនជញ្ជីងផង ការដែលវាទន្ទេញចាំនោះទៅជាឥតប្រយោជន៍ទៅវិញ បើក្មេងនេះលេងរៀនទៅនឹងយកចំណេះនេះទៅប្រើការមិនបាន ហេតុដូច្នេះគ្រូបង្រៀនវិធីនេះដូចជាបង្រៀនវត្ថុសារប្រយោជន៍ គ្រូ ឲ្យមានមេរង្វាស់រង្វាល់កាន់នៅដៃជាដរាប គឺម៉ែត្រសំរាប់វាស់ លីត្រសំរាប់វាល់ ជញ្ជីងនឹងកូនជញ្ជីងសំរាប់ថ្លឹង ហើយប្រើឲ្យវាស់ឲ្យវាល់ឬឲ្យថ្លឹងរបស់ផ្សេង ៗ ទាល់តែកូនសិស្សយល់ ហើយចេះវាស់វាល់ថ្លឹងប្រាកដផង វេលាកូនសិស្សវាស់ឬវាល់ឬថ្លឹងរបស់អ្វី ៗ រួចហើយត្រូវឲ្យសរសេរចំនួននោះនៅក្ដារខៀនបញ្ជូរ ធ្វើដូច្នេះ កូនសិស្សនឹងសប្បាយចិត្តឃើញប្រយោជន៍ដែលបានរៀនចេះនោះ ហើយចេះយកទៅធ្វើការឯផ្ទះទៀតផង ជាការទម្លាប់កូនសិស្សមិនឲ្យកាន់ច្រឡំ គឺមិនឲ្យវាស់ផ្ដេសផ្ដាសដូចជាប្រវែង ៥ សង់ទីម៉ែត្រទៅថាជា៥ដេស៊ីម៉ែត្រ ។

សង្ខេបសេចក្ដីទៅ គឺការបង្រៀនរង្វាស់រង្វាល់ត្រូវឲ្យមានមេរង្វាស់រង្វាល់ ហើយបង្ខំកូនសិស្សឲ្យបេះ វាស់ បេះវាល់ បេះថ្លឹងប្រាកដ ៗ

ល. ម៉ានិត្យង៍

ស្រង់ចេញពីកិច្ចសិក្សា បឋមវិជ្ជាបារាំងសែស - ខេមរៈ

ខែមារ្ស – អាវ្រិល ឆ្នាំ ១៩៣៨

ឱ. ឈ.

---

## ឧត្តមផ្កាង

# ត្រាព្រះសង្ហារប្រទេសឥណ្ឌៀ

កាលព្រះបាទធម្មាសោក គង់ព្រះជន្មនៅឡើយទ្រង់បានសាងត្រាព្រះសង្ហារសម្រាប់ប្រទេសឥណ្ឌៀ មានរចនាជារូបសិង្ហបួនឈរប្រទល់គ្នា ជាន់លើបល្ល័ង្ក យកមុខប្រឈមទៅទិសទាំងបួន នៅមុខបល្ល័ង្កមានរចនាកង់ធម្មចក្រ ត្រាព្រះសង្ហារនេះគេបានប្រថាប់រៀងមកទល់ឥឡូវនេះដែរ ។ នៅក្រសួងការបរទេស និងស្ថានទូតឥណ្ឌៀដូចជាទ្វីបអឺរុប ប្រទេសអាមេរិក និងប្រទេសអាស៊ី បើព្រះមហាក្សត្រិយ៍ឬប្រធានាធិបតីប្រថាប់ត្រាព្រះសង្ហារយ៉ាងណា រដ្ឋមន្ត្រីក្រសួងការបរទេសនិងរាជទូតក៏ត្រូវប្រថាប់ត្រាដូចគ្នា លើកតែព្រះមហាក្សត្រិយ៍និងប្រធានាធិបតីប្រថាបដោយទឹកមាស រីឯរដ្ឋមន្ត្រីក្រសួងការបរទេសនិងរាជទូត បោះប្រថាប់ពណ៌ផ្សេង ៗ ខុសពីទឹកមាស ។ ឯត្រាព្រះសង្ហារនៃប្រទេសកម្ពុជាយើង នានាប្រទេសបានស្គាល់មកយូរអង្វែងហើយ ដោយសារប្រទេសយើងបានបោះពុម្ពសៀវភៅកំណត់ពាំល្ខោនព្រះរាជទ្រព្យនិងព្រះរាជពិធីបុណ្យផ្សេងៗ ក្នុងព្រះបរមរាជវាំងមានបោះត្រាព្រះសង្ហារនៅលើក្បាលសៀវភៅ ហើយពួកបរទេសដែលចូលមកលេងក្នុងប្រទេសយើងគេបាននាំសៀវភៅនោះទៅបោះពុម្ពផ្សាយនៅប្រទេសគេមានដាក់ត្រាព្រះសង្ហារប្រទេសយើងផង ដូចកាលរាជា

កិសេកព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្សប្រទេសយើងបានផ្ញើសៀវភៅ កំណត់ព្រះរាជពិធីបុណ្យមួយក្បាលទៅថ្វាយព្រះអង្គម្ចាស់ "តំរង់" ទីប្រឹក្សាអមព្រះចៅប្រទេសថៃ ហើសទ្រង់បានបោះពុម្ពផ្សាយជាសៀវ ភៅរឿងពិធីបុណ្យរាជាភិសេក ជាអក្សរសៀម មានជាប់ព្រះសង្ហារ នៅនោះដែរ ។

ឈោគ ខ. ឈុំ

## ពន្យល់ពាក្យ-

ព្រះបាទធម្មាសោក = ព្រះនាមព្រះមហាក្សត្រិយ៍ប្រទេសឥណ្ឌា ។

ព្រះសង្ហារ = (ម.ថ.សង៉ហារ) ន. គ្រាសម្រាប់ក្សត្រិយ៍ ។

បល្ល័ង្ក = (ម.ថ.ប័ល-ល័ង) ន. ព្រះទែនសម្រាប់ព្រះពុទ្ធ ឬព្រះរាជាគង់ពែនព្រះបាទ ។

ធម្មចក្រ ឬ ធម្មចក្ក = (ម.ថ.ធ័ម:ច័ក) ន. ចក្រគឺធម៌ដូចកង់ធម៌ ដែលមានដំណើរវិលដូចកង់រទេះ ។

សមរម្យ = (ម.ថ.សំរំ) គុ ឬ កិ.វិ. ដែលត្រូវបែបមិនខាសក្លែក ។

ប្រថាប់គ្រា = បោះគ្រា ។

បរទេស = (ម.ថ.បរទេស ឬ ប៉:រ:ទេស) ន. ប្រទេសដទៃ ។

រាជាភិសេក = ពិធីស្រោចទឹកក្រូសនឹងទឹកស័ង្ខ តាំងព្រះរាជាឲ្យពេញ ជាក្សត្រិយ៍ទ្រង់រាជ្យ

វេវចនៈ: – ជន្មៈ កំណើត ជីវិត ព្រាណ... . ។

អក្ខរាវិរុទ្ធ: – ជន្ម ( ន្ម ) បល្ល័ង្ក ( ង្ក ) ពុម្ព ( ម្ព ) បុណ្យ (ណ្យ)

ស្វរតេទ– ព្រះសង្ហាប្រទេសឥណ្ឌា បានកសាងតាំងពីរាជ្យព្រះមហាក្សត្រណា ។ គ្រានោះមានរូបភាពដូចម្តេច ។ ព្រះមហាក្សត្រនឹងនាម៉ឺនសព្វមុខមន្ត្រីប្រថាប់គ្រាព្រះសង្ហារដូចម្តេច ។ ហេតុអ្វីគំនានាប្រទេសស្គាល់ព្រះសង្ហារខ្មែរយើង ។

---

ឧត្តមដ្ឋាន

---

## គ្រឿងអាវុធនិងកំបាំងមនុស្សជាន់ដើម

គ្រឿងអាវុធដែលខ្លាំងពូកែស័ក្តិសិទ្ធិល្អ ឬសមសួននោះ មិនមែនដោយមានលក្ខណៈល្អ ដែលមើលឃើញនឹងភ្នែកឬដោយសារដែកនោះទេ គ្រឿងអាវុធដែលចំណាប់ល្អពូកែដោយផ្លូវវិជ្ជាការខាងសាសនានឹងមន្តអាគមដែលគ្រូជុំបញ្ចូលទៅក្នុងអាវុធនោះ ៗ ឬដោយវិធីបញ្ចុះលេខយ័ន្ត ។ ហេតុនេះបានជាគ្រឿងអាវុធរបស់អ្នកចម្បាំងអ្នកដទៃទៀតមិនហ៊ានទៅប៉ះពាល់ទេ វៀរលែងតែចម្បាំងប៉ុណ្ណោះ ។ ក្នុងវេលាសាន្តគ្រាណា គេតែងយកគ្រឿងអាវុធអស់នោះទៅល្បងមើល ដើម្បី

ឲ្យឃើញថាមានមន្តវិជ្ជាការកាន់គ្រឿងអាវុធនោះ ៗ ហើយទើបគេមានសង្ឃឹមថា នឹងមានជ័យជំនះ ហេតុបានជាមុននឹងយកអាវុធចេញប្រើសឹងបានល្បងមើលឃើញថាមាំពូកែមែន ៗ

សេចក្តីក្រេវក្រោធរបស់ពួកមនុស្សសម័យជាន់ដើម មិនមែនគេខឹងដូចជាយើងយល់នោះទេ គឺដែលយើងឃើញគេខឹងញ័រសាច់ព្រួយចិត្តជាពន្ទឹកនោះ ដោយគេខ្លាចក្រែងយើងប្រើអំណាចសក្តិសិទ្ធិពួកគេឬធ្វើឲ្យខូចអន្តរាយដល់ទំនៀមទំលាប់របស់គេ តែតាមពិតនោះពួកនេះខ្លាចសេចក្តីលោភពីយើងទៅទេតើ ៗ ប្រសិនបើយើងឃើញគេមិនមានមាត់ពាក្យច្រើនដូចជាយើងៗយល់ថាមនុស្សបែបនេះជាអ្នកខឹងច្រើនពុំបាន ព្រោះមនុស្សពួកនេះមិនសូវបេះធ្វើឲ្យអ្នកណាខឹងទេ ឬគ្រាន់តែធ្វើឲ្យអ្នកដទៃប្រែទឹកមុខក៏ពុំសូវមានដែរ ព្រោះការស្គាល់កម្លាំងទឹកចិត្តរបស់គេជាមុន ឬនិស្ស័យសន្តានចិត្តរបស់មនុស្សដែលគេត្រូវការ នៅជាមួយផងនេះជាការមានប្រយោជន៍ណាស់ ៗ ធម្មតាមនុស្សសម័យជាន់ដើម មិនសូវបេះនិយាយទទឹងទាស់ជាទំនាស់ដល់ចិត្ត របស់អ្នកដែលមកនិយាយជាមួយនឹងគេនោះទេ ៗ

លោក ប. ឈុំ

## ពន្យល់ពាក្យ.–

អាវុធ = ន. គ្រឿងប្រហារ ឬចម្បាំងផ្សេងៗ

ស័ក្តិសិទ្ធ= ន. ការសម្រេចដោយអំណាច ។ គុ. ដែលខ្លាំងពូកែ

យ័ន្ត ឬ យ័ន្ត្រ= ( ម. ថ. យ័ន ) ន. ដំណើរការពារ គំនូសដែល
គូសលើសំពត់ស ឬ ក្រដាស

សាន្តត្រាណ= ក្សេមក្សាន្ត – សុខស្រួល

ក្រេវក្រោធ= កំហឹងខ្លាំង – ខឹងខ្លាំង

រោចនៈ= ក្រោធ – កំហឹង – សេចក្តីខឹង

សទិសសព្ទៈ= វៀរ – កិ. វៀរចាកទុច្ចរិត ។ វា បុ. ស. សិស្សវាឈើ

វារៈ= កិ. ត្រឡប់វារឡើងច្រើន ។

អក្ខរាវិរុទ្ធៈ= អាវុធ ( ធ ) ស័ក្តិសិទ្ធិ ( ក្តិ-ទ្ធិ ) មន្ត ( ន្ត ) យ័ន្ត ឬ
យ័ន្ត្រ ( ន្ត-ន្ត្រ )

ប៉ះ= ( ះ ) សាន្តត្រាណ ( ន្ត– ណ )

សូរពោធ– គ្រឿងអាវុធមនុស្សជាន់ដើម ដែលល្អហើយខ្លាំង ពូកែនោះមានលក្ខណៈដូចម្តេច ។ មុននឹងទៅច្បាំងគេរៀបពិធីយ៉ាងដូចម្តេចខ្លះ ។ មនុស្សជាន់ដើមដែលគេខឹងម្តង ៗ ដោយហេតុអ្វី ។

## មជ្ឈិមដ្ឋានទី ២

# ទឹងកើតខាត

មានពពែពីរតួ ដើរមកទល់ជួបគ្នា នៅកណ្ដាលស្ពានមួយ ពពែមួយថា ស្ពាននេះចំពោះដើរបានតែតួមួយ ៗ នឹងដើរជៀសគ្នាពុំបាន បើដូចនេះត្រូវតែអ្នកឯងថយទៅក្រោយសិន ចាំយើងដើរទៅដល់ចុងស្ពានកាលណា សឹមអ្នកឯងដើរទៅចុះ ។

ឯពពែមួយទៀតក៏ថា យើងឯងមានការជាបន្ទាន់ ត្រូវតែអ្នកឯងថយទៅក្រោយសិន ចាំយើងដើរទៅដល់ចុងស្ពានកាលណា សឹមអ្នកឯងដើរទៅហោង៍ ពពែទាំងពីរសឹងពុំព្រមថយក្រោយដូចគ្នា កាន់មានះរៀង ខួនក៏ក្បាលបង្ហាញស្នែងអួតទន្ទាំរគ្នា ក៏បោលសំរុកដល់គ្នារុញទៅរុញមកប្រឹងចំកោងខ្លួន សូរសព្ទស្នែងគ្រឹប ៗ ដោយកំឡាំងពោសោមោហោ ប៉ាំងបិទឥតបញ្ញានឹងសម្រុបគ្នា ដល់គ្នាទាល់តែធ្លាក់ពីលើស្ពានទៅក្នុងទឹកទាំងពីរតួ បានក្ដីវេទនាដោយធ្លាក់ឈ្លក់ទឹក មានអាការផ្សេង ៗ ចំប្រឹងត្រដរហែលទឹក ស្ទើរតែពុំរួចដល់មាត់ព្រែក ។

លោក ជ.ឈុំ

ពន្យល់ពាក្យ.–

បន្ទាន់ = កិ. ប្រញាប់ឡើង

មានះ = សេចក្ដីរឹងត្អឹង

ទោសោ = ម. ទោសៈ – កើតទោសា = កើតកំហឹង

មោហោ = សំ. ម. មោហៈ = អវិជ្ជា – សេចក្ដីវង្វេង

អក្ខរាវិរុទ្ធ = ខឹង ( ឹ ) = បង (ង) – ត្រូវ (វ) – ស្មើរ (រ)

សួរដោល.– ពាក់តែពីរត្អូនេះកើតវិវាទ ទឹងគ្នាពីរឿងអ្វី? ពាក់តែបាត់បញ្ញានិយាយសម្របគ្នាពុំបានដោយហេតុអ្វី? បានក្ដីដូចម្ដេចទៀត ខ្លួន ។ល។

---

## មជ្ឈិមដ្ឋានទី ២

# ជើងឈើពុកជាងជើងកំណើត

យើងនៅក្នុងលោកវេលានេះ គឺនៅក្នុងកណ្ដាលឧបាយកលផ្សេង ៗ ទុកជាយើងមានគំនិតគិតគូរប៉ិនប្រសប់យ៉ាងណាក៏ដោយ យើងនៅតែមិនអាចជៀសរួច ឬគេចឲ្យផុតពីសេចក្ដីពិតបានឡើយ ។

នៅក្នុងប្រទេសបារាំងសែសវេលាមុននេះ ថាមានបុរសម្នាក់កំបុតជើង យកជើងឈើមកបូមធ្វើជំនួសជើងកំណើត បុរសជើងឈើនេះកើតសតិវិបល្លាសឡើង យ៉ាងណាមិនប្រាកដច្បាស់ ស្រាប់តែស្ទុះក្រទឹក្រទាឡើងសម្លាប់មនុស្សទាំងឡាយមិនថាអ្នកណាទេ ទម្រាំតែចាប់ខ្លួនបុរសជើងឈើនោះបាន អ្នកនោះបានសម្លាប់មនុស្សអស់សែសិបប្រាំនាក់ ។

លុះប៉ូលិសចាប់ខ្លួនបុរសនោះបាន ក៏មានសេចក្ដីសង្ស័យពល់គ្នាថា ធ្វើដូចម្ដេចទើបវាសម្លាប់គេបានដល់ទៅសែសិបប្រាំនាក់ ក្នុងទីបំផុតចាប់បានគាំភ្លើងដៃតូចមួយលាក់កណ្ដប់ក្នុងជើងឈើ ដោះប្រហោងមានខ្សែលួសចងយោងពីកៃគាំភ្លើងទៅ ហើយគាត់កាន់ចុងខ្សែសម្រាប់បាញ់ ។

លោក ប.ឈុំ

ពន្យល់ពាក្យ.–

បូម = កិ. ក្លែងលាយបូលដោយបន្ទំថាជាពិតជាមែន ។

សតិ = (ម.ជ.សៈតិ) ន. ស្មារតី - គំនិត

វិបល្លាស= (ម.ជ.វិបល្លាស) ន (សំ- វិបយ៉ាស) ការផ្លាស់ប្រែ

វេវចន= វិបល្លាស = វិបរិត - វិបត្តិ

សទិសសព្ទ= បាទ- ន ព្រះបាទ ព្រាក់បាទ ។ បាទ- និ ខ្ញុំប្របាទម្ចាស់ ។ បាត ន.បាតដៃ បាត្រ- ន បាត្រលោក ។

អក្ខរាវិរុទ្ធ = វិបល្លាស ( ល្លាស ) - ស្អុះ ( ះ ) មិន ( ិ ) - បាទ ( ទ ) ពោះ ( ះ ) ។

សួរដោទ — មនុស្សដើមឈើនេះមានកលឧបាយដូចម្ដេច ។ លុះគេចាប់បានខ្លួន គេឃើញមានអ្វីនៅក្នុងដើមឈើ ។ អ្នកយល់ឃើញថា មនុស្សនេះមានគំនិតអាក្រក់យ៉ាងហ្នឹងមកពីអ្វី ។ល។

---

មជ្ឈិមដ្ឋានទី ១

## រៀនមើល - ហាត់ភាសា

### មាតាបិតានិងបុត្រធីតា

ក្នុងសកលលោក បើរាប់តែចំនួនមនុស្ស មានមាតាបិតានិងបុត្រប្រុសស្រីច្រើនជាអនេក មិនមែនក្រទេ ព្រោះមនុស្សដែលកើតត ៗ គ្នា មកនោះមានច្រើនណាស់ ដែលជាកម្រមាននោះ គឺមិនសូវមានមាតាបិតានិងបុត្រធីតា ដែលចេះទំនុកបំរុងសង្គ្រោះគ្នាឲ្យបានត្រឹមត្រូវតាមបែបបទ ច្រើនតែលើសៗ ខ្វះៗ ត្រូវត្រង់ណោះខុសត្រង់ណោះ មិនសព្វគ្រប់ ព្រោះ

ហេតុនោះបានជាថា កម្រមានក្នុងលោក ។ ឯបែបបទដែលមាតាបិតាត្រូវទំនុកបំរុងបុត្រធិតានោះ មានប្រាំយ៉ាង៖

១– ចិញ្ចឹមបីបាច់រក្សាកូនដោយប្រពៃ មិនទម្រើសកូនឲ្យធំចិត្តឡើងបាន កាលណាឃើញកូនធ្វើអំពើអាក្រក់ ប្រញាប់ប្រញាល់ឃាត់ហាមយ៉ាងម៉ឺងម៉ាត់មិនបណ្តែតបណ្តោយ ប្រាប់ប្រដៅឲ្យស្គាល់ទោសទុច្ចរិតដោយជាក់ស្តែង ឲ្យកូនខ្លាចរអាពងចាលរួញចិត្តគំនិតលែងហ៊ានប្រព្រឹត្តធ្វើអំពើអាក្រក់នោះតទៅទៀត ។

២– ប្រៀនប្រដៅកូន ឲ្យកាន់សុចរិតប្រព្រឹត្តតាមគន្លងធម៌ច្បាប់ ប្រាប់ពន្យល់អំពីផលសុចរិតដោយច្បាស់លាស់ ឲ្យកូនជឿស្តាប់ស៊ប់គំនិត ពេញចិត្តស្រឡាញ់ផ្លូវត្រូវផ្លូវល្អ បង្ហឹកកូនឲ្យថ្នឹកស៊ប់ស៊ាំ ក្នុងផ្លូវសុចរិតតាំងពីតូចមក ។

៣– ប្រដៅកូនឲ្យថ្នឹកក្នុងការចេះដឹង គឺបង្ហឹកកូនឲ្យរៀនរាប់ ឲ្យរៀនគិត រៀនបូក រៀនសង រៀនចែក រៀនវាល់ រៀនវាស់ រៀនថ្លឹង រៀនគូរ រៀនសង់ស្ថានការជាដើម ឲ្យថ្នឹកតាំងពីតូចមក មិនបណ្តែតបណ្តោយឲ្យកូនខ្វាសគាំងគំនិតប្រាជ្ញាក្នុងការចេះដឹង លុះដល់កូនមានអាយុចំរើនធំល្មមឲ្យរៀនចំណេះវិជ្ជាហើយ បានទំនុកបំរុងឲ្យកូនរៀនអក្សរសាស្ត្រនិងវិជ្ជាផ្សេង ៗ តាមគួរដល់កាលៈទេសៈនិងសម័យនិយម មិនបណ្តោយឲ្យកូនល្ងង់ខ្លៅ ។

៤ - ត្រូវរៀបចំកូនឲ្យមានផ្ទះសម្បែង តាមសមគួរដល់ពូជវង្សជាតិ ត្រកូលនឹងទ្រព្យធនជាដើម ត្រូវប្រយ័ត្នកុំចាត់ការរៀបចំឲ្យហួសហេតុ ហួសទំនង បើខ្លួនក្រកុំយកតម្រាប់អ្នកមាន កុំប្រណាំងប្រជែងនឹងអ្នកមានទ្រព្យ ប្រយ័ត្នកុំឲ្យដាច់បង់ទ្រព្យធនទាល់តែដល់ថ្នាក់លក់ដីបញ្ចាំកេរ្តិ៍ ឬជំពាក់បំណុលគេរុំកោះត្រាំត្រែងយូរ ត្រូវរៀបចំកូនឲ្យសមល្មមដល់ការគួរកុំឲ្យខុសទំនង ។

៥ - ត្រូវលៃលកបំណាយប្រាក់ឲ្យកូនរៀនបំណេះវិជ្ជា ត្រូវទិញគ្រឿងប្រដាប់ឲ្យកូនប្រើប្រាស់តាក់តែងខ្លួនខ្លះ ឲ្យកូនមានសម្លៀកបំពាក់គ្រប់គ្រាន់ ឲ្យប្រាក់កាសចាយវាយខ្លះ មិនត្បិតត្បៀតហួសប្រមាណ ក្នុងវេលាចែកទ្រព្យសម្បាប់ត្រូវចែកឲ្យហើយស្រេច ឲ្យត្រឹមត្រូវតាមលក្ខណៈច្បាប់ កុំទុកឱកាសឲ្យកូនឈ្លោះប្រកែកដណ្ដើមគ្នាជាខាងក្រោយ ។

អាននិងពន្យល់ពាក្យ.

បុត្រធិតា (អ. ថ. ធិដា)= កូនប្រុសស្រី ។

សកលឬសាកល (អ.ថ.សៈកៈលៈ ឬសាកល់) គុ. ឬ កិ.វិ.= ដែលទូទៅទាំងអស់ ទាំងមូល ។

សកលលោក= លោកទាំងមូល ។

អនេក= គុ. (អ.ថ.អ:នេក)= ច្រើន ច្រើនក្រៃ ។

រអា= កិ. ឬ គុ. ត្រាន់ ។ រអាចិត្ត=ត្រាន់ចិត្ត ។

ឱវាទ: ប្រដៅ= ទូន្មាន ឲ្យឱវាទ ស្ដីថា បង្ហឹក ។

សួរដោទ.– មាតាបិមានឹងបុត្រធិតា ថែបយ៉ាងណាដែលថា កម្រមាន ? មាតាបិតាត្រូវទំនុកបំរុងកូន ដោយថែបបទប៉ុន្មានយ៉ាង ? បទទី ១ យ៉ាងដូចម្ដេច ? ។ល។

ច្បាប់ក្រម

ព្រះជនកហៅគណា បង្កើតអាត្មា ឲ្យមានសុរិលផង រក្សាពីតូច
មិនឲ្យមានហ្មង អស់សុខទុក្ខផង ពុំដែលនឹងឆ្អន់ ។

---

អាទិកាដ្ឋាន

## បង្រៀនពាក្យ–ហាត់ភាសា

អាទិត្យទី១.– ឆ្អឹង (អដ្ឋិសន្ធិលិក)

ឆាម.– ឆ្អឹងខ្នង ឆ្អឹងជំនី ឆ្អឹងលលាដ៍ក្បាល ឆ្អឹងស្មាបប្រជៀវ ឆ្អឹងដងកាំបិត ឆ្អឹងដៃ ឆ្អឹងម្រាមដៃ ឆ្អឹងម្រាមជើង ឆ្អឹងដើមដៃ ឆ្អឹងកំភួនដៃ ឆ្អឹងភ្លៅ ឆ្អឹងកំភួនជើង ឆ្អឹងត្រគាក ។

គុណនាម.– មូល សំប៉ែត វែង ខ្លី រឹង ទន់ កោង ត្រង់ រដិប រដុប គ្រាស់ ស្តើង ។

កិរិយាសព្ទ.– បាក់ដៃ-ជើង កាត់ដៃ-ជើង បែកលលាដ៍ក្បាល ដកឬកាត់ម្រាមដៃ-ជើង ។

ហាត់ភាសា.– ធ្អឹងកងខ្នងយើងតាំងប៉ុន្មានប្រមូលមកហៅថាអ្វី? នៅដៃ-ជើងមានធ្អឹងអ្វីខ្លះ ? អ្នកស្គាល់ធ្អឹងវែងអ្វីខ្លះ ? ធ្អឹងជំនីមានប៉ុន្មាន ករ៍ដូចម្ដេច ? មកពីណាទៅដាប់ឯណា ? ធ្អឹងលលាដ៍ក្បាលយ៉ាងដូចម្ដេច ? យើងឈរត្រង់ខ្លួនបានដោយអ្វី ? (ធ្អឹងខ្នង) ធ្អឹងមេដៃ-មេជើងមានប៉ុន្មានបំណែក ? ធ្អឹងម្រាមដៃ ម្រាមជើងមានប៉ុន្មានបំណែក ?

ការហាត់សរសេរ.– ចូរបំពេញឃ្លានៅកន្លែងចន្លោះខាងក្រោមនេះ ៖

រូបមនុស្សយើងមានអវយវៈ...... អវយវៈលើនិមួយ ៗ មកភ្ជាប់នឹងដងខ្លួននៅស្មា ឯស្មានោះមានធ្អឹងពីរ ធ្អឹងក្រោយហៅថា......ឯធ្អឹងខាងមុខហៅថា...... អវយវៈក្រោមនិមួយ ៗ មកប្រសព្វភ្ជាប់គ្នា ខាងក្រោយត្រង់កន្លែងចុង.....ធ្អឹងលលាដ៍ក្បាល.....។ មានធ្អឹងខ្លះវែង គឺដូចជា... ។ មានធ្អឹងខ្លះខ្លីគឺដូចជា...... ។

## បង្រៀនមើល

### ឆ្អឹងសន្លាក់ ឬ គណ្ឋិកៈ

*សៀវភៅវត្ថុស្ងាតព្យាយន៍ការទិកដ្ឋានទំព័រ ៩-១០*

*អានពាក្យ.- អបលគណ្ឋិក=(អៈបៈលៈគ័នថិកៈ ។*

*តម្រូវពាក្យ.- ដំ=ពក ។ តរ=ត ។ មឹន=មិន ។ ប្រសប់គ្នា= ប្រសព្វគ្នា ។*

## សរសេរតាមសូត្រ

### អំពីឆ្អឹង

*មនុស្សយើងឈរត្រង់ខ្លួនបានដោយសារឆ្អឹងខ្នង ឆ្អឹងដៃ ជើង ឆ្អឹងសន្លាក់ដៃ-ជើង ។ល។ ឆ្អឹងជាប់គ្នាទៅវិញទៅមក ទឹងសរសៃតសាច់ ។ ក្បាលមានឆ្អឹងលលាដ៍ដូចជាប្រអប់មួយមានខួរនៅក្នុងនោះ ។ ទៅខាងមុខមានឆ្អឹងមុខ គឺឆ្អឹងប្រមុះ ឆ្អឹងថ្គាល់ទឹងឆ្អឹងថ្គាម ។ ដងខ្លួនមានឆ្អឹងទ្រនុងខ្នង ឆ្អឹងជំនីរទឹងឆ្អឹងទ្រូង ។ បើអ្នកស្ទាបដងខ្លួនអ្នកមើល អ្នកនឹងឃើញឆ្អឹងអណ្ដែតមួយ គឺឆ្អឹងអង្គញ់សម្រាប់ទប់ជើងកុំឲ្យភ្លាត់ទៅខាងមុខ ។*

ពាក្យពិបាក.– ឈរ (រ) ដោយសារ (រ) សន្ទាក់ សរសៃ អន្តញ់ អណ្តែត ។

## តែងសេចក្តី

ចូរអ្នកអធិប្បាយអំពីសិស្សខំរៀនសូត្រម្នាក់ ដែលអ្នកបានស្គាល់ជាប្រាកដ ។

ពំនសតែង

សេចក្តីផ្តើម.– ឈ្មោះ អាយុ ថ្នាក់ដែលសិស្សនោះរៀន ។

សេចក្តីពប់រៀប.–នៅក្នុងកន្លែងរៀនសិស្សនោះប្រព្រឹត្តដូចម្តេចខ្លះ? វេលាចេញពីសាលារៀនទៅផ្ទះ ? ចេញពីផ្ទះទៅសាលារៀន ?

សេចក្តីបញ្ចប់.– អ្នកយល់ឃើញដូចម្តេច អំពីសិស្សដែលខំរៀន?

## អក្សរផ្ចង់

ឃ ឈ យ ល ស ណ

សាលាជំនុំ ឃុំអាឃី អាឃ្មឈរយំ យាយយូ ឃ្មរធំ ។

# បង្រៀនពាក្យ - ហាត់ភាសា

## អាទិត្យទី៦.— អំពីសំពត់

នាម.— សំពត់អំបោះ ទេសឯក ផាឌិប ស្បៃ អ៊ូ កាមី សំពត់អន្ទូញ សំពត់ខ្មៅ កំណាត់ផ្កា កំណាត់ឆ្នូត កំណាត់ពណ៌ សំពត់សូត្រ (សំពត់ព្រែ) ព្រែឡាញ់ ព្រែលាត ព្រែពោឡា ព្រែផ្កា ព្រែឈួន ហូល ផាមួង ល្បើក បរបាប់ ។

គុណនាម.- ស្តើង ក្រាស់ ម៉ដ្ឋ គគ្រើម គគ្រាត រលីង រលើប ជាប់ ផុយ ទន់ រឹង ភ្លឺផ្លេក ចាំង សាប់ ។

កិរិយាសព្ទ.— ដេរសំពត់ កាត់ស្បៃ បោក អ៊ុតព្រែលាត ផ្តុកសំពត់ ជ្រលក់សំពត់ ផុលហូល ស្រេះសំពត់ព្រែ ប៉ាក់កាមី ។

ហាត់ភាសា.— សំឡៀកប្លាសសម្រាប់ធ្វើអ្វី ? សំពត់អំបោះពណ៌សស្តើងសាច់ម៉ដ្ឋរលីងហើយជិតល្អ គេហៅថាសំពត់អ្វី ? (ទេសឯក) ចុះបើសំពត់នោះសាច់ក្រាស់រឹងគគ្រាតហៅថាសំពត់អ្វីវិញ ? (ផាឌិប) កំណាត់អ្វីដែលគេយកធ្វើមុង ?

ការហាត់មាត់ទទេ.– ១- ចូររកពាក្យដែលជាកិរិយា ដែលគ្រូទើបនិយាយបាន មកដាក់ខាងមុខនាម ដែលមានក្នុងវិធីបង្រៀនពាក្យនេះ ៖

ឧទាហរណ៍.– តថ្ងៃស្បៃ ៗ ល ៗ

២– ចូររកនាមសព្ទ ដែលគ្រូទើបនិយាយបាន មកដាក់ខាងមុខគុណនាម ដែលមានក្នុងវិធីបង្រៀនពាក្យ ៖

ឧទាហរណ៍.– ស្បៃស្តើង ៗ ផាឱបក្រាស់ ៗ ល ៗ

៣– ចូររកពាក្យផ្ទុយនឹងពាក្យទាំងនេះ ៖ គគ្រាត ផិតខៃ ស្តើង ផាប់ ក្ញី ៗ ល ៗ

ការហាត់សរសេរ.– ១– ចូរតែងជាឃ្លានឹងពាក្យនេះ ៖ ជ្រលក់ ព្រែផ្កា កំណាត់ឆ្នូត ព្រែឡាញ់ សំពត់ហូល

២– ចូរបំពេញពាក្យនៅក្នុងចន្លោះខាងក្រោមនេះ ៖ ស្រីខ្មែរច្រើនតែចូលចិត្តយកទេសឯកសមក.....(ផ្តក) នឹងទឹកមក្លឿធ្វើជា... (សំពត់ខ្មៅ) ៗ នៅស្រុកអាយសំពត់ដែលល្អឆើតជាងគេ គឺ......(សំពត់ហូល) សព្វថ្ងៃនេះប្រុស ៗ អ្នកស្រុកអាយច្រើនយក..... ព្រែឈូនប្ដ..... (ព្រែលាត) មកធ្វើជាខោ-អាវ ៗ សំពត់អំបោះ.....(ផុយ) ហើយសាប់.....(គគ្រើម) មិន.....(រលីង) ដូចសំពត់សូត្រទេ ៗ

## បង្រៀនមើល

ការរវៃអំបោះហើយនឹងត្បាញសំពត់

(សៀវភៅវត្ថុស្វាធ្យាយន៍អាទិកដ្ឋានទំព័រ ៤៩)

## សរសេរតាមសូត្រ

### សំលៀកបំពាក់

មនុស្សត្រូវតែមានសំលៀកបំពាក់បិទបាំងខ្លួន ដើម្បីការពារនឹងកំដៅព្រះអាទិត្យ ឬរងានឹងសត្វខាំ ហើយនឹងបិទបាំងកេរ្ដិ៍ខ្មាសផង តាមទំនៀមខ្មែរយើង គេស្លៀកសំពត់ចងក្បិនទាំងប្រុសទាំងស្រី ។ សំពត់មានច្រើនបែប គឺសំពត់អំបោះនឹងសំពត់សូត្រ សំពត់ខ្លះមានគំនូរក្បាច់ណាស់ ។

ខ្មែរប្រុស ៗ ពាក់អាវកត្រង់មានឡេវយ៉ាងញឹក ស្រី ៗ ពាក់អាវបំពង់វែងធ្លាក់ដល់ជង្គង់ហើយបង់កក្រមា ។ ទាំងប្រុសទាំងស្រីកាត់សក់ជ្រងខ្លី ប៉ុន្ដែខ្មែរយើងចាប់យកតំរាប់តាមជនជាតិបរទេសណាស់ មាន

ប្រុសខ្លះស្លៀកខោពាក់អាវតាមបារាំង - ចិន - យួន · ហើយនិយាយថា មិនចង់ស្លៀកសំពត់ទេ ព្រោះមិនចេះមូរក្បិន ។

សរសេរពាក្យពីធាតុ.– សត្វ ព្រះអាទិត្យ កើត ជនជាតិ បរទេស – បារាំង – មូរក្បិន – ទំនៀម – អំបោះកីផ្កា – ជន្ទង់ ។

## បង្រៀនពាក្យ – ហាត់ភាសា

### អាទិត្យទី ៣. គ្រឿងជ្រលក់សំពត់

នាម.– ផ្លែមក្លៀ សំបកស្វាយព្រៃ សម្បកកំកែង សម្បកស្នួល សម្បកព្រហូត ដើមត្រុំ មើមរមៀត ខ្ទឹមខ្ទុរ ខ្ទឹមឃ្មេ ផ្លែដំពូ លុកឃុត ដក់គាំ ស្បែង ស្លាប់ ល័ក្ដ ត្រុំ ក្បុង មរ ។

គុណនាម.– ខ្មៅ ខៀវ លឿង ក្រហម បៃតង ស្វាយ ផាយ ពីបាក ស្រស់ ខ្ចី ក្រមៅ សព្វ ធ្វក ដិត ។

កិរិយាសព្ទ.– ជ្រលក់សំពត់ ត្រាំសម្បកស្វាយព្រៃ គ្រវីល័ក្ដ ប្រមោកស្បូត្រ លាយក្បុង ប្រឡាច់មរ ពូតសំពត់ ហាលស្លាប់ ស្ងោះសម្បកស្នួល គាស់មើមរមៀត ។

## ហាត់ភាសា.–　　តាំសិស្សនិយាយ

នឹងជ្រលក់សំពត់អំបោះ ឬសំពត់សូត្រឲ្យបានពណ៌ខៀវ ខ្មែរយើងធ្វើនឹងអ្វីខ្លះ ? បើពណ៌ក្រហមទុំគេធ្វើនឹងអ្វី ? បើជ្រលក់សូត្រឲ្យបានពណ៌លឿងស្រស់ គេជ្រលក់នឹងអ្វី ? នៅស្រុកខ្មែរយើងគេជ្រលក់សំពត់ឲ្យបានពណ៌ខៀវខ្ចីនឹងអ្វី ? លុកឃុតពណ៌ដូចម្ដេច ?

វិធីហាត់សរសេរ.– ១– ចូលតែងជាឃ្លានឹងពាក្យ ៖

"ស្វាយ" ប៉ុន្តែឲ្យប្រើសេចក្ដីផ្សេងពីគ្នា ។

ឧទាហរណ៍.– ដើមស្វាយនេះមានផ្លែច្រើន ។ សំពត់សូត្រនេះពណ៌ស្វាយ ។ នៅលើក្បាលសេះមានសក់មួយគព្ចុំហៅថាសក់ស្វាយ ។ បុរសនេះកើតរោគស្វាយ ។

២– ចូរធ្វើឃ្លានឹងពាក្យជាសាយគនិបាត ៖ "ដើម្បី" នឹងជ្រលក់សំពត់អំបោះ ដើម្បីឲ្យបានពណ៌ខៀវខ្ចី គេត្រូវប្រឡាប់សំពត់នេះក្នុងទឹកផ្ទះ ចូរតែងពាក្យបីឃ្លាឲ្យដូចគ្នា ប៉ុន្តែឲ្យនិយាយពីរបស់អ្វីផ្សេងវិញ ។

ឧទាហរណ៍. ដើម្បីនឹងបេះផ្លែមក្លៀ គេត្រូវកាប់មែកវាទម្លាក់ចុះ ។

ដើម្បីទៅសាលារៀនឲ្យទាន់ម៉ោង ត្រូវតែធ្វើដំណើរឲ្យលឿន ។ ត្រូវខំរៀនមេសូត្រឲ្យចាំស្ទាត់ ដើម្បីកុំឲ្យត្រូវទណ្ឌកម្ម ។

ចូរតែងពាក្យបីឃ្លានឹងកិរិយាសព្ទនេះ "ប្រមោក" ប៉ុន្តែឲ្យប្រើសេចក្តីផ្សេងពីគ្នា ។

ឧទាហរណ៍ – ស្រីនេះបេះប្រមោកសូត្រស្អាតណាស់ ។ កូននេះម្តាយវាដូចជាគេប្រមោក ប៉ុន្តែវាមិនពាក់ពាលសោះ ។ រឿងនេះគេប្រមោកមកលើយើងហើយ ។

## បង្រៀនមើល

### ការជ្រលក់សំពត់

(សៀវភៅវិត្តស្វាធ្យាយន៍អាទិកដ្ឋានទំព័រ ១៥២) ។

កែតម្រូវពាក្យ.– ប្រហូត = ព្រហូត ។ លាក់ = ល័ក្ខឬល័ខ ។

សូត = សូត្រ ។

## សរសេរតាមសូត្រ

### ដើមត្រុំ

ត្រុំជារុក្ខជាតិតូច កំពស់ពីចិតសិបសង់ទីម៉ែត្រ ទៅដល់មួយម៉ែត្រ

ដើមវាស្ទឹតដុះតំរៀបជាជួ ផ្កាមានបង្កោមពណ៌ក្រហម នៅខាងក្នុងផ្លែមានគ្រាប់តូច ៗ ពណ៌ខៀវ ។

គេដាំត្រុំនៅដីខ្សាច់សើម ។ គេព្រោះគ្រាប់ឬគេដាំជាជួរបម្លាយពីគ្នាប្រហែលហុកសិបសង់ទីម៉ែត្រ ឯចំការត្រុំនោះត្រូវរក្សាឲ្យស្អាតហ្មត់ចត់ ហើយឧស្សាហ៍បោចស្មៅចេញផង ។ ដល់កាលណាត្រុំមានផ្កា គេកាត់មែកទុកកំពស់ពីព្រះធរណីប្រហែលម្ភៃសង់ទីម៉ែត្រ ក្រោយនោះបន្តិចគេឃើញខ្នែងថ្មីដុះឡើងរហ័សណាស់ លុះបានប្រាំមួយអាទិត្យឬពីរខែ គេប្រូតត្រុំបានម្តងទៀត បើនៅលើព្រះធរណីណាដែលល្អ គេប្រូតបានបីដង ។

ដំណាំត្រុំគេមិនទុកឲ្យនៅក្នុងចំការឲ្យហួសមួយឆ្នាំទេ

ពាក្យពីបាក.— ទុក រុក្ខជាតិ ដុះ ពណ៌ ហ្មត់ចត់ ឧស្សាហ៍ ធរណី កំពស់ ខ្នែង ។

## តែងសេចក្តី

១— ចូរនិយាយអំពីសម្លៀកបំពាក់របស់អ្នកស្រុក ដែលអ្នកធ្លាប់បានឃើញហើយ មានខុសគ្នាដូចម្តេចខ្លះ ? អ្នកចូលចិត្តសម្លៀកបំពាក់បែបណា ? ព្រោះអ្វីបានជាអ្នកចូលចិត្តសម្លៀកបំពាក់បែបនោះ ? ។

២– លោកគ្រូអ្នកមានទូន្មានអ្នកថាឲ្យសំអាតខ្លួនប្រាណ សំអាតសំលៀកបំពាក់ ផ្ទះសម្បែង ចំណីអាហារ ហើយនឹងទឹកផឹក ។ ចូរអ្នកអធិប្បាយអំពីសេចក្ដីដែលលោកទូន្មាន ថាដូចម្ដេចខ្លះ? ការសំអាតមានប្រយោជន៍ដូចម្ដេចខ្លះ? ។

## គំរូសេចក្ដីទី២

លោកគ្រូខ្ញុំបានឲ្យដម្បូន្មានខ្ញុំបាទអំពីការសំអាតថាដូច្នេះ៖ ចូរអ្នកទាំងឡាយពេញចិត្តនឹងការសំអាតខ្លួនប្រាណ សំអាតគេហដ្ឋានដែលសម្រាប់អាស្រ័យនៅ សំអាតគ្រឿងប្រដាប់សម្រាប់ស្លៀកពាក់ សំអាតភោជនាហារសម្រាប់បរិភោគ. នឹងទឹកផឹក ហើយនឹងទឹកសម្រាប់ប្រើប្រាស បើអ្នកមិនចូលចិត្តនឹងការសំអាតនេះទេ នោះខ្លួនប្រាណរបស់អ្នកដែលគ្របដណ្ដប់អប់រុំដោយគ្រឿងស្លៀកបំពាក់កខ្វក់ នឹងគ្រឿងប្រើប្រាស មិនស្អាតនោះ នឹងអាចបណ្ដាលឲ្យអ្នកកើតរោគផ្សេងៗ បើរូបកាយមានរោគហើយ ដូចម្ដេចឡើយនឹងឲ្យចិត្តដែលជ្រកនៅខាងក្នុងរីករាយសប្បាយបាន បើចិត្តមិនរីករាយហើយ ធ្វើម្ដេចឡើយនឹងរៀនសូត្របានចំរើន ។

ហេតុនេះ ឃើញថាការមិនសំអាតជាមូលហេតុនាំឲ្យកើតរោគ រោគជាមេចង្រៃមកផ្ដិល ឯការសំអាតជាហេតុនាំឲ្យគ្មានរោគ បើរូបកាយគ្មានរោគហើយ ចិត្តក៏នឹងរីករាយសប្បាយបាន ហើយនឹងប្រកបកិច្ចការរៀន

សូត្របានចំរើន បើដូច្នេះចូលអ្នកទាំងឡាយស្រឡាញ់ រាប់អាន ពេញចិត្តនឹងការសំអាតនេះចុះ ។

---

បរិច្ឆេទណាដ្ឋាន

## បង្រៀនពាក្យនឹងភាសា

អាទិត្យទី១ នេសាទត្រី

នាម នេសាទ, ព្រាន ( អ្នកធ្វើរបរនឹងចាប់សត្វព្រៃ ឬ សត្វទឹកយកមកចិញ្ចឹមជីវិត ហៅថា នេសាទឬព្រាន) ព្រានសន្ទូច, ព្រានសំណាញ់, ព្រានឆ្នូស ព្រានសំពស, ព្រានមង, អួន, អញ្ចង,

គុណនាម អ្នកនេសាទស្ទាក់ ឆ្នែង ការនេសាទបរិបូណ៌, ប្រសើរ, មាំមួន រប៉ិចរប៉ុ ។

កិរិយា - នេសាទត្រី, ដឹកអួន, បង់សំណាញ់, ពាក់មង ស្ទូសអញ្ចាង, កៀរត្រី, រាយអួន, ហាលត្រី, ប្រឡាក់ត្រី, ។

ភាសា— កន្លែងនេសាទធំៗមាននៅកន្លែងណា ? ទន្លេបឹងទន្លេសាប ឈូងសមុទ្រនៅកំពត ) មនុស្សជាតិអ្វីដែលធ្វើជារបរនេសាទដ៏ធំ ៗ (យួន ចាម) ។

ពាក្យដែលត្រូវបង្រៀនគេទៅទៀតក្នុងអាទិត្យដម្បូង

នាម= នេសាទុបករណ៍ (គ្រឿងប្រដាប់សំរាប់នេសាទ) ថ្នង ឈ្នក់, លប, ផន, ទ្រូ, ប្បូក, ស្នូ, សន្ទូច, ព្រួល, លាន់, ឈ្នាង, អន្ទ្រុត, តន, សំណាញ់ ។

គុណនាម= ជួសមាំ សម្រាមសញ្ញាក ប្បូកស្រួច អួនរៃង ។

កិរិយា= ណាមង ភយអួន លើកផន ផងត្រី ទ្រាប ដាក់ទ្រូ ពយប្បូក សត្រី ទសសម្រាស់ ត្រាំឈ្នាង ដឹកតន ក្រុងត្រី រុត, អញ្ចាត់ ផ្ចាប ។

## រៀនមើល

## ១ អំពីនេសាទត្រី

(សៀវភៅខេមរៈ បរិ. ទំព័រ ៨៧)

ពន្យល់ពាក្យ ទុយ= ដុំសាច់ ឬ ប្រហុក ដែលគេចិតនៅផ្ទៃសន្ទូច កំសួល= ដុំឈើឬស្មោចងក្អាប់នឹងខ្សែសន្ទូច ដើម្បីឲ្យសន្ទូចអណ្ដែត ។

ពាក្យខុស ត្រីស់ ឲ្យសរសេរត្រីស់ ។ ការស្រេ ឲ្យសរសេរ ការស្រ័យ

## ២ អំពីពេលអាស្រ័យបាយផ្ទាញ់

សៀវភៅដំរីដល ទំព័រ ៤៥

ពាក្យសរសេរខុស– អាស្រ័យសម្ម ស្មគ្គ ដោយសា ត្រូវ សរសេរ អាស្រ័យ សម្ម ស្មគ្រ ដោយសារ ។

### សរសេរតាមសូត្រ

សុំឲ្យយករឿងមើលមកធ្វើជួបប្រក្រតី ប៉ុន្តែសុំកុំគួបនឹងបង្អឹក សិស្សឲ្យសរសេរពាក្យពីបាកជាមុននៅក្ដារខ្មៀនដូចពាក្យ = នេសាទ សន្ទូច ដើរ កន្ត្រោង បោះ លិច រ៉ាត់ អាស្រ័យ ។

### បង្រៀនពាក្យនិងភាសា

អានិក្យទី២.– ផិលនៃនេសាទ

នាម.– ត្រី, បង្កង, អណ្ដើក, កន្ធាយ, បបែល, អន្ទង់លៀស,

ត្រី ខ្សឹង ៗ ត្រីច្រា, ត្រីព្រួល, ត្រីគល់រាំង, ត្រីត្រសក់, ត្រីព្រលូង, ត្រីរ៉ស់ ត្រីឆ្តោ ត្រីបង្វា ត្រីកែស ត្រីក្រពាត់ ត្រីឆ្តាំង ត្រីពោ ឆ្លាម ៗ

គុណនាម ៈ- ត្រីព្រលូងពុល, ឆ្លាមកាច, ត្រីគល់រាំងធំ, ស្បែកបវែបលគគ្រាត, ខ្លាញ់ខាប់, ត្រីឆ្អើរក្រៀម, បង្កងស្រស់, ត្រីងៀតស្ងួត ៗ

កិរិយា.— ឆ្អើត្រី, វះពោះ, ស្រកា, ប្រៀកងៀត, ប្រឡាក់អំបិល ហាល ឆ្អើរ, រំលាស់, បំហៀរ, លក់, បញ្ជូន, ជូន ៗ

## រៀនមើល

### ១ ការប្រយោជន៍ដល់អ្នកទាំងពួង

(សៀវភៅខេមរភាសា ទំព័រ ១០)

ពាក្យសរសេរខុសក្នុងសៀវភៅត្រូវកែជា កំហុស, សូត្រ, មិនដោយសារ, នាយក ត្រួត ពាក្យ ទោទ

## សរសេរតាមសូត្រ

( សុំឱ្យធ្វើដូចប្រក្រតី គឺយករៀនមើលមកធ្វើ)

## បង្រៀនពាក្យនឹងភាសា

អាទិត្យទី៣ ថ្ងៃទី៤– អាហារកើតឡើងអំពីផលនៃនេសាទ

នាម– ងៀត ឆ្អើរ, ប្រហុក ផ្អក, កាពិ, ទឹកត្រី, បង្គា, ម្ហូប ។

គុណនាម– ងៀតក្រៀម, ត្រីឆ្អើរស្វិត, ស្រួយ, ប្រហុកខ្ទះឈ្ងុយ, ផ្អកជូរ, ខុល, កាពិប្រៃ, ទឹកត្រីឈ្ងុយ, ផ្ចា, គ្រឿង ។

កិរិយា– ឆ្អើរត្រី, ធ្វើប្រហុក, ជាវផ្អក, រំងាស់ទឹកត្រី, ប្រោះ, ស្ងោចៀន ចំអិន បរិភោគ ។

## បង្រៀនមើល

បិផ្សាផ្តិកសត្វ-ត្រី

( វត្ថុស្វាធ្យាយន៍ ទំព័រ ៣៨ )

ពាក្យខុសក្នុងសៀវភៅត្រូវកែ– ស្រមុទ្រ ជា សមុទ្រ ឬ សមុទ្ទ ។

កុមារដ្ឋា

## បង្រៀនពាក្យនិងភាសា

អាទិត្យទី ១ -

### អំពីក្រុមញាតិ

នាម - វង្សត្រកូល, ពូជ, (ដំណមនុស្សត ៗ ដោយ ឈាមជាមួយ) សាខា (មែក) សាខាញាតិ, ញាតិ ៧ សន្តាន (ញាតិ ៧ ជួរ) ញាតិ-ពន្ធ (ញាតិមិនតគ្នាដោយ ឈាមជាមួយ) ញាតិជិត, ញាតិឆ្ងាយ, ញាតិក្នុងស្រុក ។

គុណនាម.- ខ្ពស់, ទាប, ថោក, ថ្លៃ, មាន, ក្រ, រហេមរហាម តោកយ៉ាក, ដាបដាប, ខិលខូច, ។

កិរិយាសព្ទ.- ទំនុកបំរុង, ការពារ, គោរព, បង់កេរ្តិ៍, រក្សាកេរ្តិ៍, ដៀលត្មះ ។

ហាត់ភាសា.- គេហៅថាអ្វីដំណមនុស្សដែលកើតតៗ មក? មនុស្សយ៉ាងដូចម្តេចដែលសំដីត្មះហៅថាមនុស្សឥតត្រកូល? (មនុស្សខិលខូច) ដែលហៅមនុស្សមានត្រកូល? (មនុស្សមានបុគ្គខ្ពស់) ។ ញាតិទាំងឡាយ

មានប៉ុន្មានជំពូក? (ពីរជំពូកគឺញាតិជិតនិងញាតិឆ្ងាយឬសាខាញាតិ) ។ ញាតិពន្ធនោះគឺញាតិយ៉ាងដូចម្ដេច? (គឺជាញាតិខាងប្ដីនិងខាងប្រពន្ធ) ។

អាទិត្យទី២.– អំពីក្រុមញាតិ (ត)

នាម.– ឪពុក (បិតា) ម្ដាយ (មាតា) កូនប្រុសកូនស្រី, បងប្អូន, អាយុ; ។

គុណនាម– ធំ, តូច, ក្មេង, ចាស់, លីវ, ជំទង់, ច្រើន ។

កិរិយា– បង្កើត, ចិញ្ចឹម, ថែទាំ, ស្រឡាញ់, គោរពខ្លាច, ។

ភាសា– ក្នុងក្រុមញាតិអ្នកមានអ្នកណាខ្លះ? ឪពុកម្ដាយអ្នកមានកូនប៉ុន្មាន? អ្នកណាខ្លះ? បងប្រុសអ្នកអាយុប៉ុន្មាន? គាត់មានប្រពន្ធហើយឬនៅលីវ? កូនប្រុសស្រីត្រូវធ្វើម្ដេចនឹងឪពុកម្ដាយ? បងប្អូនប្រុសស្រីត្រូវធ្វើម្ដេចនឹងគ្នា ។

អាទិត្យទី៣.– អំពីក្រុមញាតិ (ត)

នាម– ជីតា-ជីដូន, ឪពុកធំ, ម្ដាយធំ, មា, មីង, បងប្អូនជីដូនមួយ, បងប្អូនជីទួតមួយ, ចៅ, ក្មួយ, ក្មួយជីដូនមួយ ។

គុណនាម– ចាស់, ជរា, អនិច្ចកម្ម, រស់, ស្លាប់, ញ័រ (ដៃ) កោង (ខ្នង) ។

កិរិយា.– ឈ្លោះប្រកែក, គោរពប្រតិបត្តិ, ទំនុកបំរុង ស្ដាប់បង្គាប់, ទូន្មាន, និយាយរឿង ។

ភាសា= ជីតាអ្នកអាយុប៉ុន្មាន? ជីដូនអ្នកនៅរស់ឬអនិច្ចកម្មហើយ គាត់ដើរទៅណាឆ្ងាយបានឬទេ? ពីព្រោះអ្វី? ជើងដៃគាត់ដូចម្តេច? អ្នកមានឪពុកម្តាយធំឬទេ? គាត់នៅឯណា? គាត់រកស៊ីធ្វើអ្វី? គាត់មានកូនប្រុសស្រីប៉ុន្មាន? មាអ្នកត្រូវជាម្តេចនឹងឪពុកអ្នក? ដូចម្តេចដែលហៅថាបងប្អូនជីដូនមួយ? បងប្អូនជីដូនអ្នកត្រូវជាម្តេចនឹងឪពុកម្តាយអ្នក ហេតុអ្វីបានជាត្រូវគោរពប្រតិបត្តិជីដូនជីតា? ដើម្បីឲ្យឪពុកម្តាយសប្បាយចិត្ត អ្នកត្រូវធ្វើដូចម្តេច? ។

អាទិត្យទី ៤. អំពីក្រុមញាតិ (ត) ឪពុកក្មេក, ម្តាយក្មេក, បងថ្លៃ, ប្អូនថ្លៃ, កូនប្រសា, ក្មួយប្រសា ។

គុណនាម.- កាច, ស្លូត, ល្អ, អាក្រក់, សុខសប្បាយ, ឈឺ ។

កិរិយា.- និយាយគួរសម, និយាយលេង, រាប់អាន, ជួយគ្នា, ដោះទុក្ខគ្នា, ប្រកាន់ទោស, ធ្វើងក់ទ្រើវ ។

ភាសា.- បងអ្នកការប្រពន្ធពីឆ្នាំណា? ឪពុកម្តាយប្រពន្ធគាត់ត្រូវជាឪពុកអ្វីនឹងគាត់? ប្រពន្ធគាត់ត្រូវជាដូចម្តេចនឹងអ្នក? បងថ្លៃអ្នកចិត្តអាក្រក់ឬល្អ? កាចឬស្លូត? គាត់ចេះរាប់អានបងប្អូនឬទេ? គាត់គួរសមនឹងមាតាបិតាអ្នកឬទេ? គាត់ឧស្សាហ៍និយាយលេងជាមួយនឹងអ្នកឬទេ?

# រៀនមើលសរសេរ

អាទិត្យទី ១.-

## ក្រុមញាតិបង្កើត

សៀវភៅវិជ្ជាខេមរភាសាកុមារដ្ឋានទំព័រ៩៤, ៩៥,

អាទិត្យទី២.- បងប្អូនបង្កើត

វិជ្ជាខេមរភាសាកុមារដ្ឋានទំព័រ (៩៧)

អាទិត្យទី៣.- ស្រឡាញ់បងប្អូន

វិជ្ជាខេមរភាសាកុមារដ្ឋានទំព័រ (៩៩)

អាទិត្យទី៤.- ត្រូវស្រឡាញ់កោតខ្លាចជីដូនជីតា ជីដូនជីតាយើងគាត់នឿយព្រួយលំបាក ទំរំចិញ្ចឹមឪពុកម្តាយយើងដូចជាមាតាបិតាយើងនឿយហត់ទំងរកចិញ្ចឹមយើងដែរ ហើយមួយទៀតជីដូនជីតាយើងគាត់ថែទាំរក្សាយើងទៀតផង វេលាដែលឪពុកម្តាយយើងមិននៅទៅធ្វើការ; ហេតុនេះយើងត្រូវស្រឡាញ់ជីដូនជីតាយើងដូចជាយើងស្នេហាមាតាបិតាយើងដែរ ។

# តែងសេចក្តី

## សម្រាប់ប្រថមភូមបំពេញវិជ្ជា

**កម្មវិធីសម្រាប់ខែ** អត្ថាធិប្បាយអំពីសុភាសិត

**សេចក្តីតែងទី ១-** សុភាសិតមួយវគ្គមានសេចក្តីថា ៖ "ខ្លួនទីពឹងខ្លួន" ។ ចូរអ្នកធ្វើអត្ថាធិប្បាយនៃសុភាសិតនេះ ។

## គោលសេចក្តី

១- សេចក្តីផ្តើម.- គ្រប់ពេលដែលលោកគ្រូសង្កេត ឃើញកូនសិស្សបម្លងការហាត់ពីគេពុំប្រឹងគិតគូធ្វើខ្លួនឯង "ឃើញកូនសិស្សណាពុំចាំមេរៀន លោកគ្រូរំឭកកូនសិស្សនោះ ៗ ដោយពាក្យថា ៖ "ខ្លួនទីពឹងខ្លួន" ។

២- តួសេចក្តី- សុភាសិតនេះជាពាក្យរំឭកដាស់តឿនដល់ជនគ្រប់ប្រភេទ ទាំងកូនសិស្ស ទាំងអ្នកប្រកបកិច្ចការចិញ្ចឹមជីវិត ។

ក- ចំពោះកូនសិស្ស ៖ សុភាសិតនេះក្រើនឲ្យខំសន្សំចំណេះវិជ្ជាទុកក្នុងខ្លួនដោយ ៖

- ផ្ចង់ស្មារតីស្តាប់អស់ទាំងពាក្យគ្រូពន្យល់ឥតខ្ជាន ។
- ខំរៀនឲ្យចាំរត់មាត់នូវមេរៀនទាំងឡាយ ។
- ធ្វើការហាត់ផ្សេង ៗ ដោយផ្ចិតផ្ចង់

កុំឲ្យសង្ឃឹមលើរូបអ្នកដទៃឲ្យជួយជាងរូបខ្លួន ។

កូនសិស្សណាពុំខំរៀនឲ្យបេះចាំ ហើយអាងលបលួចមើលគេឯង អាងចម្លងពីគេប្រុងសង្ឃឹមឲ្យគេឯងជួយ កូនសិស្សនោះធ្វើកិច្ចការអ្វីក៏ពុំបានល្អឡើយ ចូលប្រឡងអ្វីក៏ពុំជាប់លេខឡើយ ។

២– ចំពោះអ្នកប្រកបការចិញ្ចឹមជីវិត ៖ សុភាសិតនេះប្រដៅឲ្យខំធ្វើការរកស៊ីដោយខ្លួនឯង កុំឲ្យសង្ឃឹមកម្លាំងអ្នកដទៃ កុំឲ្យផ្អែកខ្លួនលើសម្បត្តិទ្រព្យអ្នកដទៃ ទោះអ្នកនោះត្រូវជាសាច់ញាតិ ឬជាមិត្តសំឡាញ់ក៏ដោយ ។ ត្រូវបំពេញករណីយកិច្ចរបស់ខ្លួន ដោយខ្លួនឯងទើបប្រសើរ ពុំត្រូវបណ្ដោយឲ្យអ្នកដទៃឡើយ ព្រោះដោយគេពុំមែនជាអ្នកទទួលខុសត្រូវ គេនឹងធ្វើដោយខ្ជីខាជាប្រាកដ ។ ហើយផលអាក្រក់ដែលកើតឡើង នឹងធ្លាក់មកលើខ្លួនយើង ។

៣ សេចក្ដីបញ្ចប់ សុភាសិត "ខ្លួនទីពឹងខ្លួន" នេះ ពុំមែនប្រដៅកុំឲ្យយើងពឹងរកអ្នកដទៃឡើយ ពីព្រោះមនុស្សក្នុងលោកគ្មាននរណាមួយអាចរស់នៅតែឯកឯងបានឡើយ ។ សុភាសិតនេះក្រើនយើងឲ្យធ្វើកិច្ចការអ្វីដោយហ្មត់ចត់ កុំគប្បីបណ្ដែតបណ្ដោយ ។

ដូច្នេះ ខ្ញុំបាទត្រូវប្រព្រឹត្តតាមដំបូន្មានសុភាសិតនេះ ដោយទៀងទាត់ដើម្បីជាគុណប្រយោជន៍ ដល់សតិបញ្ញារបស់ខ្ញុំបាទក្នុងកិច្ចស្វែងរកចំណេះវិជ្ជា ។

សេចក្ដីតែងទី២ - ភាសិតបារាំងមួយវគ្គមានសេចក្ដីថា ៖ "គេបេះផលដែលគេបានបណ្ដុះពូជ" ។

## សេចក្ដីអធិប្បាយ

១- ចំពោះកូនសិស្ស ដែលប្រឡងធ្លាក់ លោកគ្រូតែងមានប្រសាសន៍ថា ៖ "វាបេះផលដែលវាបានបណ្ដុះពូជ" ។

២- បើស្រង់តាមអត្ថានុរូប ភាសិតមួយវគ្គនេះមានន័យឥតឃ្លៀងពីការពិតឡើយ ។ ជាពលថ្ងៃយើងអាចសង្កេតឃើញហេតុជាច្រើនដែលកើតឡើងតាមសេចក្ដីនៃភាសិតនេះ ។ កសិករដែលសាបព្រោះស្រូវពូជពុំសុទ្ធ ដូចជាស្រូវដំណើបមានលាយខ្សាយច្រើន នៅរដូវរំហើយកសិករនោះ នឹងច្រូតបានស្រូវពុំសុទ្ធដែរ ។

អ្នកដែលដាំដើមស្វាយពុំសែន នឹងពុំបានបេះផ្លែស្វាយអ្វីដទៃក្រៅពីស្វាយពុំសែន ដែលខ្លួនបានបណ្ដុះគ្រាប់ឡើយ ។

ក៏ប៉ុន្តែគេនិយមប្រើភាសិតនេះជាអត្ថាបដិរូប ។ កូនសិស្សខ្ជិលច្រអូសក្នុងកិច្ចសិក្សា តែងតែទទួលផលអាក្រក់ជានិច្ច ៖ បានពិន្ទុតិចត្រូវគ្រូស្ដីបន្ទោស ជាប់ថ្នាក់ទាប ប្រឡងពុំជាប់លេខ ។ល។

ពាណិជករដែលរកស៊ីប្រកាន់ផ្លូវទុច្ចរិត គង់តែថ្ងៃណាមួយវិនាសសម្បត្តិទ្រព្យពុំខាន ឬធ្លាក់ខ្លួនដល់ទៅជាជាប់ទុក្ខទោសផងក៏មាន ។

យុវជនដែលពុំស្តាប់ដំបូន្មានមាតាបិតា ហើយប្រព្រឹត្តអំពើអបាយ
មុខ ធ្វើខ្លួនឲ្យខូចសុខភាព ខូចសតិបញ្ញា ខូចកេរ្តិ៍ឈ្មោះដោយគេមើល
ងាយដល់ពូជអំបូរ ក្រៅពីទុក្ខទោសដែលខ្លួនត្រូវទទួលផ្ទាល់ ។

កូនសិស្សខ្ជិល ពាណិជករទុច្ចរិត យុវជនពុំស្តាប់បង្គាប់មាតាបិតា
អ្នកទាំងបីពួកនេះ ដែលទទួលផលអាក្រក់ មកពីប្រកាន់កិរិយាតាមន័យ
ភាសិតនេះដែលកើតឡើងពីការសង្កេត ។ បើពុំកែគំនិតទេ ត្រឡប់
ជាក្តៅក្រហាយនឹងព្រងក់ស្នាវិញ ជនទាំងនេះបានឈ្មោះថាជាអ្នកដើរ
សន្សឹមទៅកាន់សេចក្តីវិនាសអន្តរាយសេចក្តីទុក្ខ ។

៣= ភាសិត ៖ "គេបេះផលដែលគេបានបណ្តុះពូជ" នេះមាន
ន័យត្រូវណាស់ យើងទទួលផលល្អឬអាក្រក់ តាមអំពើដែលយើងបាន
បំពេញជាប្រាកដ ។ ខ្ញុំបាទត្រូវចងចាំភាសិតនេះទុកជាគតិតទៅ ដើម្បី
ទប់ខ្លួនកុំឲ្យធ្លាក់ទៅក្នុងមហន្តរាយ ។

---

## អាទិកដ្ឋាន

---

## តែងសេចក្តី ទី ១

ចូរអ្នកអធិប្បាយអំពីឆ្នាំ ខែ អាទិត្យ ទិនថៃ្ង តាមពាក្យចោទខាង
ក្រោមនេះ ។

អ្នកបានសំគាល់ឃើញឆ្នាំមានចំនួនប៉ុន្មាន គឺឆ្នាំអ្វីខ្លះ ? ក្នុងមួយឆ្នាំមានប៉ុន្មានខែ គឺខែអ្វីខ្លះ ? ក្នុងមួយខែមានប៉ុន្មានអាទិត្យ ? ក្នុងមួយអាទិត្យមានប៉ុន្មានថ្ងៃ គឺថ្ងៃអ្វីខ្លះ ។

## សេចក្ដីអធិប្បាយ

ខ្ញុំបាទបានសំគាល់ឆ្នាំឃើញមានចំនួន ១២ គឺឆ្នាំ ជូត ឆ្លូវ ខាល ថោះ រោង ម្សាញ់ មមី មមែ វក រកា ច កុរ ។ ក្នុងមួយឆ្នាំមាន ១២ខែ គឺខែ មករា កុម្ភៈ មិនា មេសា ឧសភា មិថុនា កក្កដា សីហា កញ្ញា តុលា វិច្ឆិកា ធ្នូ ។ ក្នុងមួយខែមានបួនអាទិត្យ ក្នុងមួយអាទិត្យមាន ៧ ថ្ងៃ គឺថ្ងៃអាទិត្យ ចន្ទ អង្គារ ពុធ ព្រហស្បត៍ សុក្រ សៅរ៍ ។

## តែងសេចក្ដី ទី ២

ចូរតែងសេចក្ដីអធិប្បាយអំពីភ្លៀងតាមពាក្យចោទខាងក្រោមនេះ ។

នៅស្រុកខ្មែរយើងមានភ្លៀងច្រើននៅរដូវណា ? មុនភ្លៀងអ្នកឃើញមានអ្វី នឹងឮសូរអ្វីនៅលើមេឃ ។ លុះយូរបន្តិចទៅអ្នកឃើញមានអ្វីស្រក់ចុះមកពីលើមេឃ ។

ទឹកភ្លៀងហូរទៅឯណាខ្លះ ? នៅរដូវនោះអ្នកធ្វើស្រែធ្វើអ្វី ?

អ្នកនៅទន្លេធ្វើអ្វី ? ទឹកទន្លេស្ទឹងព្រែកឡើងឬស្រក ? អ្នកចូលចិត្តទឹកភ្លៀងឬទេ ? ព្រោះអ្វី ? ។

## តែងសេចក្ដី ទី ៣

## អំពីធ្វើដំណើរទៅស្រុកស្រែនៅរដូវភ្ជួររាស់

សូមលោកគ្រូរៀបចំរឿងតែងនេះផងចុះ

---

## បរិច្ឆណាដ្ឋាន

---

## តែងសេចក្ដី ទី ១

ចូរតែងសេចក្ដីអធិប្បាយអំពីសត្វស្រុកមានសត្វអ្វីខ្លះ ? សត្វទាំងអស់នោះខុសគ្នាដូចម្ដេចខ្លះ ? សត្វនិមួយ ៗ មានប្រយោជន៍ដូចម្ដេចខ្លះ ? យើងត្រូវធ្វើដូចម្ដេចនឹងសត្វស្រុក ?

## គំរូតែងសេចក្ដីទី ១

សត្វស្រុកគឺ ៖ គោ ក្របី សេះ ឆ្កែ ឆ្មា ជ្រូក មាន់ ទា ក្ងាន ។ សត្វស្រុកមិនដូចគ្នាទាំងអស់ទេ សត្វខ្លះមានជើងបួន មានរោមដុះពាសពេញខ្លួន សត្វខ្លះមានជើង ២ បំអេង ២ ខ្លួនដុះស្លាប ។ សត្វនិមួយ ៗ មានប្រយោជន៍ផ្សេងគ្នា ។ ឆ្កែចាំផ្ទះ ឆ្មាចាប់កណ្ដុរ ក្របីគោអូស

រទេះ អូសនង្គ័ល សេះធ្វើជំនិះ ។ មាន់ ទា ក្ងាន ជ្រូក ឲ្យពង កូន និងសាច់មកយើងធ្វើជាអាហារ ។

សត្វស្រុកមានប្រយោជន៍នឹងយើងណាស់ ត្រូវថែទាំវាឲ្យល្អ បំប៉ន ចំណីវាឲ្យគ្រប់គ្រាន់ មិនត្រូវធ្វើបាបវាទេ ។

## តែងសេចក្ដីទី ២

ចូរតែងសេចក្ដីអធិប្បាយអំពីសត្វឆ្កែមួយ តាមពាក្យចោទខាងក្រោមនេះ

អ្នកមានចិញ្ចឹមឆ្កែឬទេ? ឆ្កែអ្នកអាយុប៉ុន្មានឆ្នាំហើយ? អ្នកឲ្យឈ្មោះវាអាអី? ពីព្រោះអ្វីបានជាឲ្យឈ្មោះវាដូច្នោះ? ឆ្កែអ្នកតូចឬធំ? កាចឬស្លូត? ខ្ជិលឬឧស្សាហ៍? ពីព្រោះអ្វីបានជាអ្នកចិញ្ចឹមឆ្កែ ។

## តែងសេចក្ដីទី ៣

ចូរតែងសេចក្ដីអធិប្បាយអំពីសត្វព្រៃមានសត្វអ្វីខ្លះ ។ សត្វអ្វីខ្លះដែលជាសត្វកាច ។ សត្វអ្វីខ្លះដែលជាសត្វស្លូត ។ គេបាញ់ប្រើស រមាំង ក្ដាន់យកអ្វីវា ។ គេបាញ់សត្វដំរីយកអ្វីវា ។ បើដើរទៅក្នុងព្រៃគេខ្លាចសត្វអ្វីខ្លះ ។ ពីព្រោះអ្វីបានជាគេខ្លាចសត្វខ្លា ដំរី ពស់ ។

## តែងសេចក្ដីទី ៤

### អំពីសត្វល្អិត

សូមលោកគ្រូរៀបចំរឿងតែងផងចុះ

# កុមារដ្ឋាន

## នព្វន្ត

ក្នុងខែនេះគ្រូបង្រៀនសិស្សឲ្យចេះរាប់ ចេះអាន ចេះសរសេរចំនួនពីរ ៨០ ដល់ ១០០ ។ គ្រូបង្រៀនឲ្យចេះធ្វើលេខបូក - លេខសងមានត្រាទុក ឲ្យចេះគុណនឹងចែកចំនួននឹង ៤ ។

មេរៀនទី១ - រៀនរាប់ រៀនអាន – រៀនសរសេរចំនួនពី៨០ ដល់ ៩៤ ។

របស់សំរាប់បង្រៀន - ចង្កឹះបាច់ ៨ បាច់និងចង្កឹះរាយ ១០ ឬប្រាក់កាក់១០សេន ៨ និងលុយសេន១០ ។

### របៀបបង្រៀន–

១ មតិសំខ្យា.– ឲ្យសិស្សរាប់បន្ថែមបួន ៗ ពី១ដល់៨០ រាប់បន្ថយ ៤ ពី ៨០ មក ១ វិញ ។

២– ផ្សំចំនួនពី ៨០ ដល់ ៩០ គ្រូលើកចង្កឹះ ៨ បាច់បង្ហាញសិស្ស ហើយសួរថា នេះចង្កឹះប៉ុន្មាន ។ ចង្កឹះ ៨០ ថែមចង្កឹះ ១ ទៅទៀតត្រូវជាចង្កឹះប៉ុន្មាន ។ គ្រូសរសេរចំនួន ៨១ នៅលើក្តារខៀន ហើយ

ពន្យល់របៀបសរសេរចំនួននោះ ( លេខ៨ នៅខ្ទង់ដប់ លេខ១នៅខ្ទង់រាយ ) ឲ្យសិស្សអានចំនួន ៨១ ហើយឲ្យសរសេរនៅលើក្ដារខៀន ។ ធ្វើតាមរបៀបនេះរហូតដល់ចំនួន ៩០ ។

៣– ការហាត់អានចំនួន គ្រូបង្អុលចំនួនដែលសរសេរនៅលើក្ដារខៀនឲ្យសិស្សអាន ឬថាចំនួនឲ្យសិស្សបង្អុល ឬឲ្យសិស្សម្នាក់ថាចំនួនឲ្យសិស្សឯទៀតបង្អុល ឬឲ្យសិស្សម្នាក់បង្អុលចំនួនឲ្យសិស្សឯទៀតថា

៤– ការរៀនសរសេរចំនួន – គ្រូថាចំនួនឲ្យសិស្សសរសេរនៅក្ដារខៀន តាមរបៀបឡាម៉ារទីនីញែរ ។

៥– ការហាត់មាត់ទទេ– លេខប៉ុន្មាននៅខ្ទង់ដប់ លេខប៉ុន្មាននៅខ្ទង់រាយ ក្នុងចំនួន ៨៣. ៨៥. ៨៧. ៨២. ៨៩ ។

ត្រូវជាប៉ុន្មានបើគេបន្ថែម ៤ ទៅលើ ៧៩.៨៣. ៨៥. ៨៦. ៨៤. ៨១ ។

ត្រូវជាប៉ុន្មានបើគេបន្ថយ ៤ ពី ៨៧ - ៨៩ -៨៤. ៨៥ ។

៦– ការហាត់សរសេរនៅក្នុងសៀវភៅ

ចំណោទ.– ម្ដាយខ្ញុំមានប្រាក់ ៨៧ រៀល ។ គាត់ចាយម្ដងអស់ ៣០ រៀល ម្ដងទៀតអស់ ២៧ រៀល ។ គាត់ចាយទាំងពីរដងអស់.. .......រៀល ហើយគាត់ត្រូវនៅសល់ប្រាក់......រៀលទៀត ។

មេរៀនទី ២– ចំនួនដល់ ៩០ លេខបូកមានត្រាទុក ។

របស់សំរាប់បង្រៀន  បង្កើះបាច់ ៨ បាច់ នឹងបង្កើះរាយ ឬប្រាក់កាក់ ១០ សេន នឹងលុយសេន ។

## របៀបបង្រៀន

១- មតិសំខាន់  ឲ្យសិស្សរាប់បង្កើះឬលុយបន្ថែមបួន ៗ ពីមួយដល់ ៩០ ។

២ ពន្យល់របៀបធ្វើលេខបូកមានត្រាទុក — ឲ្យសិស្សម្នាក់កាន់ប្រាក់កាក់៣ កាក់នឹងសេន៧ (៣៧ស) ម្នាក់ទៀតកាន់ ៤ កាក់នឹងសេន ៦ (៤៦ស) តើសិស្សទាំងពីរនាក់មានប៉ុន្មានសេន ។

គ្រូតាំងលេខបូកនេះនៅលើក្តារខៀនហើយ

```
   ៣៧ស
 + ៤៦ស
 ─────
   ៨៣ស
```

ពន្យល់របៀបធ្វើលេខបូកមានត្រាទុកនេះ ដោយនាំសិស្សធ្វើទាំងអស់គ្នា ដោយសួរសាករកហេតុផល ហេតុអ្វីបានជាគេត្រាទុក កាលណាបានគេត្រាទុក — គេយកចំនួនត្រាទុកនោះទៅបូកនឹងចំនួនណា ? ពីព្រោះអ្វី ? ។

៣ ការហាត់បញ្ជាក់នៅលើក្តារខៀន ឲ្យសិស្សម្នាក់ឡើងទៅធ្វើលេខបូក (២៩ + ៣៥ ស) នៅលើក្តារខៀន ហើយឲ្យថាតាមដែលគាត់បានធ្វើ ។

៤ ការហាត់បញ្ចូកនៅលើក្ដារខៀន- ឲ្យសិស្សធ្វើលេខបូកខាងក្រោមនេះនៅក្ដារខៀនតាមរបៀបឡាម៉ាទីនីញ៉េរ ៖ ៤៦ + ២៥ ស= ៗ

៣៨ស + ៣៧ស= ៗលៗ

៥- ការហាត់សរសេរនៅក្នុងសៀវភៅ ៖

| | | | |
|---|---|---|---|
| ២៤ស | ៣៥ | ១៩ស | ២៣ស |
| +៤៧ស | +៤៦ | +៥៤ស | +៤៧ស |

មេរៀនទី៣- ចំនួនពី ៩០ ដល់ ១០០

ការរៀនរាប់ - រៀនអាន និងរៀនសរសេរចំនួន ៗ

មេរៀនទី៤= ចំនួនដល់ ១០០

រៀនធ្វើលេខសងមានត្រាទុក

មេរៀនទី៥= ចំនួនដល់ ១០០

រៀនគុណចំនួននឹង ៤

មេរៀនទី៦- ចំនួនដល់ ១០០

រៀនចែកចំនួនជា ៤

សូមមើលតាមរបៀបរៀបចំបង្រៀនជាគំរូខាងលើ ហើយសូមតែងការហាត់ឲ្យសព្វគ្រប់ផង ៗ

# រង្វាស់រង្វាល់

ក្នុងខែនេះត្រូវបង្រៀនអំពីប្រាក់រៀល ប្រាក់កាក់នឹងលុយសេន ដែលមានចាយក្នុងស្រុក ឲ្យសិស្សចេះចាយគិតដូរនឹងថែមថយលុយ ។

មេរៀនទី១— អំពីលុយ ១សេននឹងលុយ ៥ ។

របស់សំរាប់បង្រៀន— លុយ ១ សេន នឹងលុយ ៥ សេន ។

## របៀបបង្រៀន

១-- ការពិនិត្យ- នាំសិស្សពិនិត្យមើលលុយ ១ សេនរួចលុយ ៥ សេនទៀត អំពី ៖

ក- ទំហំ កម្រាស់ ពណ៌ ទម្ងន់ ។

ខ- អំពីរូប— អក្សរ នឹងលេខដែលមាននៅលើលុយ ។

គ- អំពីជាតិលោហធាតុដែលគេធ្វើលុយនោះ ។

ឃ- អំពីសូរលុយដែលទម្លាក់ទៅលើតុ ។

២- ការហាត់ដូរ ហាត់ថែមថយលុយ

លុយ ៥ សេន ៤ ត្រូវជាប៉ុន្មានសេន ។

លុយ ១ សេន ១៥ ត្រូវជាលុយ ៥ សេនប៉ុន្មាន ។

លុយ ៥ សេន ៤ នឹងលុយ១សេន ៧ ត្រូវជាប៉ុន្មានសេន ។

ខ្ញុំយកលុយ ៥ សេនពាទៅទិញទំអស់៣២សេនគេត្រូវថែមមកឲ្យខ្ញុំប៉ុន្មានសេនវិញ

បើខ្ញុំត្រូវទិញស្លាបប៉ាកកា១ថ្លៃ៣៧សេន តើខ្ញុំត្រូវឲ្យលុយ៥សេនទៅគេប៉ុន្មាន ហើយគេត្រូវថែមមកឲ្យខ្ញុំប៉ុន្មានវិញ ។

៣ ការហាត់សរសេរនៅក្នុងសៀវភៅ ៖

សូមតែងការហាត់នេះផង

មេរៀនទី ២.- អំពីប្រាក់កាក់ ១០ សេន និង ២០ សេន និង ៥០ សេន

មេរៀនទី ៣.- អំពីប្រាក់មួយរៀល - ប្រាក់សាច់និងប្រាក់ក្រដាស ។

មេរៀនទី ៤- សាបត្រៀនឡើងវិញ ។

ការចំណាំ.- ក្នុងការបង្ហាត់សិស្សពិនិត្យក្តី ថែមថយក្តី ដូរក្តី សូមរកលុយគ្រប់បែបនោះ មកឲ្យសិស្សឃើញដោយដាក់ស្តែងកុំខាន ។

---

បរិញ្ញាណដ្ឋាន

**នព្វន្ត**

តាមរបៀបបែកវិជ្ជាបង្រៀនក្នុងខែនេះ ត្រូវបញ្ជាក់អំពីមេលេខគុណបង្រៀនសិស្សឲ្យចេះឆ្លើយលេខគុណ នឹងលេខចែក លេខហារមានតែមួយតួ ហើយឲ្យចេះគិតគុណ ចែកនឹង ១០ ។

មេរៀនទី ១.– សាបង្រៀនអំពីមេលេខគុណ ជារបៀបបញ្ជាក់ឲ្យដឹងថាសិស្សចេះមេលេខគុណច្បាស់ហើយឬនៅ ។

របៀបបង្រៀន.– សួរសាកបញ្ជាក់អំពីមេលេខគុណ ដូចជា៖ ៦ × ៣ = ។ ៧ × ៥ = ។ ៤ × ៩ = ។ល។ (៦បីដង ត្រូវជាប៉ុន្មាន ។ ៧ ប្រាំដង ត្រូវជាប៉ុន្មាន ។ ៤ ប្រាំបួនដងត្រូវជាប៉ុន្មាន ។) សួរបែបនេះឲ្យច្រើន ដើម្បីឲ្យសិស្សចាំច្បាស់នូវមេលេខគុណ ។ សូមផ្លាស់ប្តូររបៀបបង្រៀនខាងលើនេះ ដោយសួរឲ្យសិស្សឆ្លើយដោយមាត់ទទេខ្លះ ឆ្លើយដោយសរសេរនៅលើក្តារឆ្ពនខ្លះ ។

ការហាត់សរសេរនៅក្នុងសៀវភៅ

១– ចូរគុណចំនួនខាងក្រោមនេះដោយគំនិត

៧ × ៤ = ...។ ៥ × ៦ = ....។ ៩ × ៧ = ....។

៣ × ៨ = ...។ ៧ × ២ = ....។ ៨ × ៨ = ....។

ក្នុង ៣៥ មាន ៧ ប៉ុន្មានដង ។ ក្នុង ៦៣ មាន ៩ ប៉ុន្មានដង ។ ក្នុង ៤២ មាន ៦ ប៉ុន្មានដង ។

ចំណោទៈ— ម្ដាយខ្ញុំគាត់លក់កូនមាន់ ៨ ថ្លៃ ៣៛ ក្នុងកូនមាន់ ១ ហើយគាត់យកប្រាក់នោះទៅទិញ សាច់ជ្រូកថ្លៃ ៦៛ ក្នុង ១ នាឡិ តើគាត់ត្រូវបានសាច់ជ្រូកប៉ុន្មាននាឡិ ។

មេរៀនទី ២ៈ— រៀនគុណចំនួនទីធំលេខមួយតួ ។

របៀបបង្រៀន.—

១— ចោទសួរសិស្សអំពីមេលេខគុណដូចរបៀបបង្រៀនខាងលើ ។

២— ពន្យល់របៀបធ្វើលេខគុណ ៖

សៀវភៅមើល ១ ក្បាលថ្លៃ ៣២៛ តើសៀវភៅនោះ ៤ ត្រូវជាថ្លៃប៉ុន្មាន ។ ត្រូវធ្វើលេខគុណ (៣២៛ × ៤) នេះនៅលើក្ដារខៀនឲ្យសិស្សមើលទាំងអស់គ្នា

៣ - ការបញ្ជាក់នៅលើក្ដារខៀន.=

ឲ្យសិស្សម្នាក់ឡើងធ្វើលេខគុណនៅលើក្ដារខៀន ហើយសួរសាកអំពីរបៀបដែលវាបានធ្វើ ។ ឲ្យសិស្សឯទៀតថារបៀបធ្វើលេខគុណ ។

៤— ការហាត់បញ្ជាក់នៅលើក្ដារឆ្នួន :

៥៧៛ × ៣ = ។ ៦៩៛ × ៥ = ។ ២១៧៛ × ២ =

៥– ការហាត់សរសេរនៅក្នុងសៀវភៅ

ក) ចូរធ្វើលេខខាងក្រោមនេះ

| | | | |
|---|---|---|---|
| ២៥៛ | ៧៩៛ | ១៤៧៛ | ១២៥៛ |
| ×៧ | ×៥ | ×៣ | ×៦ |

ខ) ចំណោទ– ឪពុកខ្ញុំគាត់មានប្រាក់ ៧៩៣ រៀល ទិញស្រូវ ៧ ហាបថ្លៃ ៥៧៛ ក្នុងមួយហាប ។ តើគាត់ត្រូវនៅសល់ប្រាក់ប៉ុន្មានទៀត ។

មេរៀនទី ៣.– រៀនចែកចំនួនធំនឹងលេខមួយតួ ។

របៀបបង្រៀន– ធ្វើតាមរបៀបបង្រៀន ធ្វើលេខគុណខាងលើនេះ ។

ការហាត់សរសេរលើសៀវភៅ

១– ចូរធ្វើលេខខាងក្រោមនេះ

៤៧៦៛ | ៤  ១៧៥៛ | ៥  ៣៥០៛ | ៧

២– ចំណោទ– ឪពុកខ្ញុំគាត់ទិញស្រូវ ៦ ហាបថ្លៃ ៤៥០៛០០ តើស្រូវ ១ – ហាបថ្លៃប៉ុន្មាន ។ បើគេទិញស្រូវនោះ ៩ ហាបត្រូវជាប៉ុន្មាន ។

## វង្វាស់វង្វាល់

ក្នុងខែនេះត្រូវបង្រៀនអំពីលុយ-កាក់ប្រាក់ ដែលមានចាយក្នុងប្រទេសឥណ្ឌូចិន ។

**របៀបបង្រៀន** មានរបៀបចំនួនជាគំរូនៅថ្នាក់កុមារដ្ឋានស្រាប់ហើយ សូមលោកគ្រូរករបស់អស់នោះមកបង្ហាញសិស្ស ឲ្យវាពិនិត្យឲ្យឃើញជាក់ស្តែង ហើយនាំហាត់ដូរបាត់ថែមថយឲ្យស្ទាត់ផង ព្រោះការទាំងនោះមានប្រយោជន៍សំខាន់បំផុត ក្នុងការចាយវាយប្រាក់ទឹងការសំគាល់ប្រាក់ក្លែងក្លាយ ។ សូមចែកថ្នាក់នោះបង្រៀនតាមពេលឲ្យសមល្មមផង សូមមើលតាមរបៀបតែងក្នុងទស្សនាវដ្តី ឆ្នាំទី ១ លេខ ៦ សំរាប់ថ្នាក់ បរិវុឌ្ឍណដ្ឋានមានសព្វគ្រប់ស្រាប់ហើយ ។

---

អាធិកាដ្ឋាន

## នព្វន្ត

អាទិត្យទី ១.– ២ ចំនួនបែងកាតគត

ការដែលមានប្រយោជន៍បំផុតនោះ ត្រូវឲ្យសិស្សធ្វើកិច្ចជាមួយផង

ឲ្យបានឃើញជាក់ស្តែងនឹងភ្នែក ។ ហេតុនេះគ្រូសិស្សម្នាក់ៗត្រូវឲ្យមានក្រដាសពីរសន្លឹក ដើម្បីនឹងធ្វើមេហេតុរៀនវិធីបែងភាគគត់នេះ ឲ្យសិស្សបានដឹងជាក់ច្បាស់ ។ យើងយកក្រដាសមួយសន្លឹកបត់ជា ៨ ចំណែកស្មើគ្នា មួយចំណែកៗហៅថាភាគ ៨ ពីក្រដាសមួយសន្លឹក-គត់ ។ ប្តូរកាត់តាមផ្នត់ឲ្យខុសបែបឲ្យខុសចំនួន ចំណែកពីមុនតែឲ្យស្មើគ្នាជានិច្ច រួចយកចំណែកមួយឬចំណែកទាំងនោះមកហៅហើយ ប្រាប់ឈ្មោះតាមដែលបែងភាគ ។ សិស្សម្នាក់ៗត្រូវឲ្យមានបន្ទាត់សំប៉ែតមួយ ធ្វើទឹងក្រដាសសយ៉ាងក្រាស់ឬបន្ទះ ដែលមានបណ្តោយមួយដេស៊ីម៉ែត្រ ។ នេះជាម៉ែត្រមួយ (បត់បាន) ។ ម៉ែត្រនេះក្រិតជាប៉ុន្មានចំណែក ចំណែកទាំងនោះស្មើគ្នាឬទេ ? បើដូច្នេះគឺជាមួយភាគដប់នៃម៉ែត្រ ដែលគេហៅដេស៊ីម៉ែត្រ ដេស៊ីម៉ែត្រគឺមួយភាគដប់តូចជាងម៉ែត្រ ។ មួយម៉ែត្រមានដប់ដេស៊ីម៉ែត្រ (គេសរសេរកាត់ ដ,ម.) ។ ឧបមាដូចជា ២ម ២០ដ.ម. ៣៤ម ៣៤០ដ.ម. ៥០ដ.ម. ៥ដម ។

វិធីហាត់គិតមាត់ទទេ- យើងគូរឬគូសបន្ទាត់មួយដេស៊ីម៉ែត្រមួយ ហើយយើងញែកម្រាមដៃមួយប្រាប់បណ្តោយដេស៊ីម៉ែត្រ ។ យើងវាស់បណ្តោយសៀវភៅមើល សៀវភៅសរសេរ ។ យើងទាយស្មានទទឹងតុ កំពស់ជើងម៉ា កំពស់ជញ្ជាំង ។ល។ យើងត្រួតត្រាផ្ទៀងវាស់ឲ្យជាក់ច្បាស់ទឹងដេស៊ីម៉ែត្រ ។ មានប៉ុន្មានដេស៊ីម៉ែត្រក្នុង ៣ ម ? ៥ ម ? ២មទឹង

កន្ទុះ ? ៤ ម ទឹងកន្ទុះ ? ខ្សែនេះមានបណ្ដោយ ១ ម. នៅសល់ប៉ុន្មានបើខ្ញុំកាត់ ២ ដ.ម. ? ៤ ដ,ម ? ដើម្បីឲ្យបានបន្ទាត់មួយបណ្ដោយ ១ ម. គេត្រូវថែមប៉ុន្មានដេស៊ីម៉ែត្រទៀតទៅនឹង ៧ ដ.ម. ទៅនឹង ៤ ដ.ម. ? ទៅនឹង ២ ដ.ម. ។ល។

វិធីហាត់សរសេរ.— ចូរធ្វើលេខដូចមានខាងក្រោមនេះ

៣០ ដ.ម + ២០ ដ.ម.= .... ដ.ម.ឬ.....ម. ។ ២ម ៥ ដ.ម. + ១ម ៣ ដម —......។ ៤ ម, ៣ ដ.ម — ៣ ម ២ ដ.ម.= ។ ១០ ម.៧ ដម — ៧ម.៩ ដ.ម..=ដ.ម. ។ ៣៥ ដ.ម. × ២..។

ចំណោទ— ខ្ញុំមានខ្សែស្រឡូបបីកំណាត់ ពីរកំណាត់មានបណ្ដោយ ៩ ដេស៊ីម៉ែត្រក្នុង១កំណាត់ មួយកំណាត់ទៀតមានបណ្ដោយ ៧ ដេស៊ីម៉ែត្រ ។ តើខ្សែស្រឡូបទាំងអស់មានបណ្ដោយប្រវែងប៉ុន្មាន។ល ។

## ២ អំពីបែងភាគដប់ពីមួយគត់

យើងវាស់បណ្ដោយតុៈត្រូវយើងឃើញ ២ ម នឹង ៤ដ. ម. ឬ ២ ម. ៤ ក្នុងភាគដប់ពីមួយម៉ែត្រគត់ ។ យើងសរសេរ ២ម. ៤ ។ យើងវាស់បណ្ដោយវត្ថុមួយទៀតយើងឃើញ ៧ ដ.ម. ឬ ៧ ក្នុងភាគដប់ពីមួយម៉ែត្រគត់យើងសរសេរ ០ម៧ ។

មេរៀនឲ្យចាំស្ទាត់— នៅក្នុងលេខបែងភាគគត់ លេខទី ១ នៅខាង

ស្ដាំ តណ្ដក់សញ្ញា គឺចំនួនភាគដប់ពីមួយគត់ ។ យើងមើលចំនួនថែវីភាគគត់ ២៤, ៣ យើងថា ២៤ គត់ ៣ ក្នុងភាគដប់ពីមួយគត់ ។

០, ៥ យើងថាប្រាំក្នុងភាគដប់ពីមួយគត់ ។

វិធីហាត់សរសេរ– ចូរសរសេរជាលេខថែងភាគគត់ ដូចមានលេខនៅខាងក្រោមនេះ ។ បួនក្នុងភាគដប់ពីមួយគត់ ។ ពីដណ្ដប់ពយម្ភគត់ ។ បើក្នុងភាគដប់ពីមួយគត់ ។ ប្រាំមួយកយម្ភគត់ ។ ប្រាំបីក្នុងភាគដប់ពីមួយគត់ ។ ប្រាំបួនក្នុងភាគដប់ពីមួយគត់ ។

បំណោទ– ខ្ញុំមានខ្សែពីរកន្ទុយ ខ្សែមួយមានប្រវែង ៤ ម. ៣ ខ្សែមួយទៀត ២ ម. ៥ ខ្ញុំចង់ខ្សែនេះតគ្នា សួរថាបណ្ដោយខ្សែទាំងពីរប៉ុន្មាន? បើខ្ញុំធ្វើដំណអស់ ០ម.១ ។ មានឈើពីរដើម ដើមទី ១ មានប្រវែង ៦ ម.២ ដើមទីពីរមានប្រវែងលើសដើមទី១ ១ ម. ៤ ។ តើដើមឈើទីពីរមានប្រវែងប៉ុន្មានម៉ែត្រ ? ឈើទាំងពីរដើមមានប្រវែងទាំងអស់ប៉ុន្មាន ? ។

អាទិត្យទី២.– ១– ថែងភាគរយពីមួយគត់ ។

– ថែងភាគពាន់ពីមួយគត់ សូមធ្វើដូចអាទិត្យមុន ហើយបំបែកវិធីហាត់គិតមាត់ទទេនឹងហាត់សរសេរ ដូចមានរៀបក្នុងអាទិត្យទី១ គ្រប់សព្វគ្រាប់ ។

អានិត្យទី ៣.– ១– លេខបូកមានក្រោចុច ។ ២– កិរិយាបូកលេខបែងភាគគត់

អានិត្យទី ៤.– ១– លេខសងមានក្រោចុច ។

លេខសងចំនួនបែងភាគគត់ ។

## រង្វាស់រង្វាល់

### អានិត្យទី ១.–ដេស៊ីលីត្រ ដេស៊ីក្រាម

រង្វាល់ចំណុះជាប្រធានមានចំនួនគត់គឺអ្វី ? រង្វាល់លីត្រនេះយើងវាល់ស្រាទំពាំងបាយជូរមួយដបបានឬទេ ? ដបទឹកក្រូចមួយដបបានឬទេ ? ហេតុអ្វីបានជាវាល់មិនបាន ដើម្បីនឹងវាស់ប្រវែងខ្លីៗជាងម៉ែត្រនោះគេប្រើអ្វី ? ។

ឯរង្វាល់ចំណុះបើនឹងវាល់វត្ថុអ្វីដែលតូចជាងលីត្រនោះ គេប្រើដេស៊ីលីត្រដូចដេស៊ីម៉ែត្រដែរ ។ គេសរសេរកាត់ ដ. ល. ។ ដេស៊ីលីត្រគឺមួយភាគដប់តូចជាងលីត្រ ហេតុដូច្នេះមួយលីត្រមានដប់ដេស៊ីលីត្រ ។ ( ១០ ដ. ល. ) ។ សូមគ្រូគ្រាផ្ទៀងមើលនឹងលីត្រហើយនឹងដេស៊ីលីត្រ វាស់នឹងដេស៊ីលីត្រហើយចាក់ទៅក្នុងលីត្រ ។ របៀបប្រើនៃដេស៊ីក្រាមក៏ដូចដេស៊ីលីត្រដែរ ។

វិធីហាត់គិតមាត់ទទេ— មានប៉ុន្មានដេស៊ីលីត្រ ក្នុង ២ លីត្រ ? ៥ លីត្រ ? ៣ លីត្រ ? ១ លីត្រកន្លះ ? ៣ លីត្រកន្លះ ? ដបមួយមានស្រាមួយលីត្រ គេបានលក់អស់ ៥ ដ. ល. នៅសល់ស្រាប៉ុន្មានដេស៊ីលីត្រទៀត ?

វិធីហាត់សរសេរ— ចូរធ្វើលេខខាងក្រោមនេះ

២៤ ក + ៤ក = ... ដ. ក. ។ ២១ ក ២ + ១៣ ក ៣ = ..... ។

៧ ក + ៣ ក ៦-....... ។ ១៤ ល ២ - ៦ ល ២ = ......... ។

២៨ ល ៩ - ៩ ល ៦.......... ។ ៥ ក ៦ + ៧ ក ២ = .. ..... ។

៦ ល ៧ × ០ ល ៦ = ... ។ ៩ ល ៥ : ៥ = ... ។ ១៦ល៤ : ៤ = ... ។

ចំណោទ— ជាងទង់ម៉ាក់ណាយមាសធ្វើខ្សែដៃមួយទម្ងន់ ១២ ក៨ ដល់ធ្វើហើយទៅខ្សែដៃនោះនៅទម្ងន់ ៨ ក ៥ ។ ទម្ងន់មាសប៉ុន្មានដែលជាងនោះកោសខាតចេញ ។ ខ្សែដៃមាសនោះថ្លៃប៉ុន្មាន បើជាងនោះលក់ក្នុងមួយក្រាមថ្លៃ៩រៀល ? ។

២— ដុទិនមួយមានស្រា ៥ ល. ៨ គេដួសស្រានោះមុនដំបូង ២ ល រួច ១ ល. ៦ ហើយគេចាក់បូលទៅវិញ ១ ល. ៩ តើដុទិននោះនៅមានស្រាប៉ុន្មានលីត្រទៀត ។

គាទគ្យទី២ សន្ទីលីត្រ សន្ទីក្រាម

សូមធ្វើដូចអាទិត្យទី ១ ហើយបំបែកវិធីហាត់គិតមាត់ទទេនឹងហាត់សរសេរឲ្យបានច្រើន ៗ

អាទិត្យទី ១-៣ មីលីម៉ែត្រ មីលីក្រាម

---

អាទិកាដ្ឋាន

វិត្តស្វាធ្យាយ

អាទិត្យទី ១

មេរៀនទី ១_ ខ្យល់អាកាស - ខ្យល់

ប្រដាប់បង្រៀន . ដប - ទឹក - ទៀន . កែវ ។

ការពិសោធន៍_ ជ្រមុជដបទៅក្នុងទឹកឲ្យសិស្សឃើញពពុះស្ទុះចេញមក ពពុះនេះគឺខ្យល់ដែលនៅក្នុងដប ។

អុជទៀនកណ្ដាលវាលឲ្យឆេះមួយសន្ទុះ រួចយកកែវមកគ្របទៀនរលត់ គឺមកពីឥតខ្យល់អាកាស ។

មេរៀនទី ២ ព្រះធរណី

ប្រដាប់បង្រៀន - កូគោល - ផ្លែក្រូចពោធិសាត់

មេរៀនសង្ខេប– ដីមានរាងមូលដូចផ្លែក្រូចពោធិសាត់មានមនុស្សនៅពាសពេញទាំងអស់ លើកលែងតែផ្ចិតដីខាងជើងនិងខាងត្បូង ។ ព្រះធរណីអណ្ដែតនៅក្នុងអាកាស ហើយវិលជុំវិញខ្លួនឯងនិងជុំវិញព្រះអាទិត្យ ។ ចំណែកណាត្រូវព្រះអាទិត្យគឺពេលថ្ងៃ ចំណែកណាដែលមិនត្រូវគឺពេលយប់ ។ ព្រះធរណីវិលខ្លួនឯងមួយថ្ងៃមួយយប់បានមួយជុំគត់មួយថ្ងៃមួយយប់មាន ២៤ ម៉ោង ។

អាទិត្យទី២.–

## មេរៀនទី ១ ទឹក

សុំមើលសៀវភៅវត្ថុស្វាធ្យាយន៍សម្រាប់បរិប្ឌណដ្ឋានទំព័រទី ៩៧. ៩៨.៩៩ ។

## មេរៀនទី ២.– បំហាយទឹក

សុំមើលសៀវភៅដដែលត្រង់ទំព័រទី ៩៩ និង ១០០ ។

អាទិត្យទី ៣

មេរៀនទី ១ ពពកនិងអ័ព្ទ

សុំមើលសៀវភៅដដែលត្រង់ទំព័រទី ១០១ និង ១០២ ។

មេរៀនទី ២ ភ្លៀង

សុំមើលសៀវភៅដដែលត្រង់ទំព័រទី ១០៣ ។

អាទិត្យទី ៤

រៀនសារដើម

សុំគ្រូរកប្រដាប់ឧណ្ហមាត្រ (thermomètre) និងប្រដាប់ស្ទង់បរិយាកាស (Baromètre) យកមកបង្ហាញហើយពន្យល់សិស្សឲ្យចេះមើលរបៀបកំណត់គំនូសតាមពេលវេលាផង ៗ

---

អាទិកដ្ឋាន ឧ

## វិធីបង្ការរោគ

### អាទិត្យទី ១.- ជម្ងឺអាសន្នរោគ

អាសន្នរោគជាជម្ងឺឆ្លង អាចកាត់ក្បាលមនុស្សតាំងភូមិ ៗ ឲ្យស្លាប់បាន ៗ ជម្ងឺនេះមានជានិច្ចជាកាលនៅប្រទេសក្លឹង្គ ហើយបានបំផ្លាញជីវិតមនុស្សជាច្រើន, នៅប្រទេសចិននិងឥណ្ឌូចិន ៗ កាលពីឆ្នាំ-១៩២៦-២៧ ជម្ងឺនេះធ្វើឲ្យវិនាសជីវិតមនុស្សនៅឥណ្ឌូចិនអស់ ១២.០០០ នាក់ ៗ

១)- លក្ខណៈ រាគរូសខ្លាំង (២០ ដាយដងក្នុង ១ ថ្ងៃ) ៗ លាមកសុទ្ធតែទឹក ហើយមានកំទេចរំងសដូចគ្រាប់អង្ករ ទឹកមូត្រថយ

ស្បែកត្រជាក់ អ្នកជម្ងឺឈឺចាប់ក្នុងខ្លួនតិចណាស់ ប៉ុន្តែចេះតែស្រេកទឹក ហើយក្អួតជាញយ ៗ អ្នកជម្ងឺឆាប់ហេវណាស់ ហើយស្លាប់ក្នុងរវាង ៣ ថ្ងៃ ៤-៥ ម៉ោងក៏មាន ។

២.- ហេតុ- ជម្ងឺនេះបណ្តាលពី "អតិសុខុមប្រាណកើតនៅក្នុងពោះវៀន រាងដូចកណ្តក់សញ្ញា ។ អតិសុខុមប្រាណនេះឆ្លងពីមនុស្សមួយ ទៅមួយដោយទឹក, បន្លែឆៅ, លាមក, សត្វល្អិតហើយគ្រឿងដែលអ្នកជម្ងឺប្រើប្រាស់ ។

៣- កិច្ចការពារ =

ក) ត្រូវដាំទឹក, ចំអិនបន្លែហើយ គ្របចំណីអាហារកុំឲ្យរុយទុំ ។

ខ) ត្រូវកាន់តាមវិធីបង្ការរោគឲ្យណាស់ ៖ បៀសវាងកុំឲ្យធ្វើអ្វីឲ្យខ្សោយកម្លាំង ។ ត្រូវលាងដៃឲ្យស្អាតមុនពេលបាយ ។

គ) ត្រូវឲ្យពេទ្យចាក់ថ្នាំដែលជាកិច្ចការពារជម្ងឺនេះកុំឲ្យរាតត្បាតបាន ។

៤- កិច្ចត្រូវធ្វើចំពោះមនុស្សកើតអាសន្នរោគ ។

ក) ត្រូវដាក់ជម្ងឺនឹងពួកគ្រួសារនៅដោយឡែក ទុកឲ្យតែមនុស្សម្នាក់ចេញចូលមើលការខុសត្រូវ ។

ខ) ឲ្យមនុស្សជម្ងឺបន្ទោបង់លាមកនឹងទឹកមូត្រក្នុងកន្ថោរ ដែលមានលាយទឹក "គ្រេស៊ីល" រួចយកទៅចាក់កប់ក្នុងរណ្តៅជំរៅ ១ ម ដោយមានចាក់កំបោរពីលើផង ។

គ)– កប់ខ្មោចស្លាប់ដោយជម្ងឺនេះក្នុងរណ្តៅជំរៅ ២ ម ជីកឲ្យឆ្ងាយពីផ្លូវទឹកទាំងឡាយ ហើយចាក់កំបោរពីលើ ។

ឃ)– បាចទឹកកំបោរពាសពេញផ្ទះ– គ្រឿងប្រដាប់ដែលមនុស្សជម្ងឺបានប្រើប្រាស់ទាំងប៉ុន្មានតោងស្ងោរឬបាចទឹក "គ្រេស៊ីល" ។

## អាទិត្យទី ២– ជម្ងឺក្អករបេង

គោលសេចក្តី.– ជារោគឆ្លងអាចចាប់គ្រប់អវយវក្នុងខ្លួន ៖ នឹងគ្រឿងប្រដាប់វិញ្ញាណ, គ្រឿងប្រដាប់រំលាយអាហារ, ស្បែកប៉ុន្តែច្រើនចាប់នៅសួត ។

១– លក្ខណៈ: រោគរបេងស៊ីសួតចាប់ពីផ្តាសាយធម្មតា រួចបណ្តាលជាក្អកឆ្លាក់ស្លេស្ម ។ ខ្លួនរេះតែក្តៅពេលអាស្រ័យស៊ីពុំបាន ។ ក្អកកាន់តែមានស្លេស្មខាប់ឡើង ហើយញាប់ឡើង ៗ ម្តង ៗ វែង ៗ កំហាកមានលាយខ្ទុះនិងឈាម ។ អ្នកជម្ងឺស្លាប់ដោយរីងសោះខ្លួន ។

២,– ហេតុ– បណ្តាលពីអតិសុខុមប្រាណ "កុក" (កុកជាឈ្មោះវេជ្ជៈបណ្ឌិត ដែលរកឃើញមេរោគនេះ) មាននៅក្នុងកំហាក– កំហាកស្ងួតទៅកើតជាធូលីហុយ នាំមេរោគនេះពេញពាស អាចចូលក្នុងសួតយើងបានតាមខ្យល់ដកដង្ហើម ។ រោគរបេងអាចឆ្លងតាមប្រដាប់

រំលាយអាហារដែរ កាលណាយើងអាស្រ័យសាច់ពុំឆ្អិនល្អ ឬយើងអាស្រ័យទឹកដោះគោកើតរបេងពុំបានដាំឲ្យឆ្អិន ។

រោគរបេងមិនមែនជម្ងឺឆ្លងស្នូរពូជឡើយ កូនអ្នករបេងកើតឡើងគ្មានជាប់រោគរបេងមកជាមួយឡើយ ។ កាលណាគេយកកូននេះចិញ្ចឹមឆ្ងាយ ពីមាតាបិតាវារស់នៅសុខសាន្តដូចគេឯង ។

៣)– កិច្ចត្រូវការពារខ្លួន –

១– បរិភោគចំណីអាហារស្អាតហើយគ្រប់គ្រាន់–នៅផ្ទះស្អាត ត្រូវហាត់ប្រាណរាល់ថ្ងៃនៅកណ្ដាលខ្យល់អាកាស ។

២– ជៀសវាងកុំឲ្យបាក់កម្លាំង–កុំឲ្យប៉ះត្រជាក់ខ្លាំង ។

៣– ត្រូវចាក់ថ្នាំទារក ។

៤– ត្រូវព្យាបាលរោគផ្ដាសាយកុំបណ្ដោយ ។

៥– ជៀសវាងកុំឲ្យខាកស្ដោះលើដី ។

៦– ធ្វើកិច្ចសម្លាប់មេរោគ ឬដុតចោលអស់ទាំងប្រដាប់ប្រដាអ្នកជម្ងឺ ។

## អាទិត្យទី ៣.– ជម្ងឺអុត

គោលសេចក្ដី – ជាជម្ងឺឆ្លងហើយជារោគប្រចាំប្រទេសឥណ្ឌូចិន ច្រើនកើតនៅប្រទេសតុងកឹងនៅរដូវត្រជាក់ ។ ច្រើនកើតកូនក្មេងនិងមនុស្សធំ ។

១- លក្ខណៈ - ចាប់ឈឺក្បាល, ឈឺខ្លួន, ក្អក, ហើយគ្រុនញាក់ហើយក្តៅយ៉ាងខ្លាំង រួចចេញកន្ទួលក្រហមពេញខ្លួននិងមុខ ។ មុខនឹងត្រូវកកែ្អកឡើងហើម ។ បន្ទាប់មកកន្ទួលនោះមានខ្ទុះ បែក ហើយក្រៀមរោគចេញទុកស្លាកស្នាមអស់មួយជីវិត ។

២- ហេតុ - គឺសុខុមប្រាណនៅក្នុងខ្ទុះនិងក្រមរដួនដោយការប៉ះពាល់អ្នកជម្ងឺដោយរុយ ។

៣- កិច្ចដែលត្រូវធ្វើនៅពេលកើតជម្ងឺ ។

១- បញ្ជូនសិស្សឲ្យទៅពេទ្យ កាលណាឃើញមានកន្ទួលលើខ្លួនវា

២- ត្រូវបណ្តុះអុតកពល់លើក ព្រោះកិច្ចនេះការពារពុំបានយូរទេ ។

កិច្ចដែលត្រូវធ្វើចំពោះអ្នកជម្ងឺ ៖

១- ត្រូវដាក់មនុស្សជម្ងឺក្នុងកន្លែងមួយដោយឡែក ឲ្យមនុស្សដែលបានបណ្តុះអុតហើយបំរើ ដេញរុយកុំឲ្យចូលក្នុងបន្ទប់នោះ ។

២- បង្អាំងជម្ងឺក្នុងបន្ទប់តាលតែជាស្រឡះ ។ ត្រូវដុតកន្ទេលខ្នើយហើយស្ងោរសំពត់ប្រដាប់ដែលអ្នកជម្ងឺបានប្រើ ។

---

បរិច្ឆណាដ្ឋាន

## វិត្តស្មាធ្យាយន៍

## អាទិត្យទី ១ - អំពីសត្វឆ្មា

សូមគ្រូចាប់ឆ្មាតូចមួយយកមកបង្រៀន នាំសិស្សពិនិត្យមើលឆ្មា ។ ក្បាលឆ្មាដូចម្ដេច ? ឲ្យសិស្សសង្កេតមើលក្រចកឆ្មា ។ ពណ៌ដូចម្ដេច ? មានអ្វីជាចំឡែកពីក្រចកសត្វឯទៀត ? សត្វអ្វីទៀតដែលមានក្រចកដូចឆ្មា ? នៅមាត់មានអ្វី ? ឯពុកមាត់នេះប្រើការដូចម្ដេច ? សូមឲ្យបើកមាត់វាមើល ធ្មេញឆ្មាមានសណ្ឋានដូចម្ដេច ? ធ្មេញណាធំជាងគេ ? ហេតុដូចម្ដេចបានជាចង្កូមនេះធំជាងធ្មេញឯទៀត ? ព្រោះឆ្មាស៊ីសាច់ចង្កូមដុះធំឡើងដើម្បីនឹងទំពាសាច់ ធ្មេញសត្វណាដែលស៊ីសាច់គឺដូច្នេះដែរ ? ( ដូចជាឆ្កែ-ខ្លា-គេ ) ។

ឲ្យសិស្សមើលខ្លួនឆ្មា - រោមឆ្មាសណ្ឋានយ៉ាងណា ? ពាល់ទៅដូចម្ដេច ។ ឲ្យសិស្សសង្កេតមើលជើងឆ្មា ឆ្មាមានជើងប៉ុន្មាន ? សត្វដែលមានជើងបួនហៅថាសត្វអ្វី ? នៅចុងជើងមានអ្វី? ក្រចកឆ្មាដូចម្ដេច? ( កោងខុបចុងក្រោមស្រួច លិបចូលលូតចេញបានតាមចិត្ត ) ឯក្រចកនេះសម្រាប់អ្វី ? ចាប់ក្រញាំសត្វជាអាហារ ។ ហេតុដូចម្ដេចបានជាឆ្មាលាក់ក្រចក កាលណាវាដើរ ? (កុំឲ្យស៊ឹក) កាលណាវាបញ្ចេញក្រចក ឲ្យឆ្មាដើរលោតដំណើរឆ្មាយ៉ាងដូចម្ដេច ? ដើរលប ៗ ដំណើរទន់ភ្លន់ ប៉ុន្តែឆាប់រហ័សណាស់ កាលណាវាចាប់សត្វស៊ីឬមួយតយុទ្ធនឹងសត្រូវ ។

សូមឲ្យគ្រូនិយាយអំពីពុតត្បាហើយតែងសេចក្ដីសង្ខេបផងចុះ ៗ

## ២- អំពីគោ

### អាទិត្យទី ២.– អំពីមាន់

វត្ថុសម្រាប់បង្រៀន– មេមាន់.ពងមាន់.រូបថ្កៃនាំសិស្សពិនិត្យមើល ក្បាលមាន់ ក្រួតនិងចំពុះមាន់ ចំពុះរឹងស្រួចសម្រាប់ចឹកអាហារ ៗ មាន អ្វីដុះរុំជុំពត់ខ្លួន ( មានរោមតូច ៗ ) រោមនេះប្រយោជន៍ដូចម្ដេច? គ្រប ដណ្ដប់ខ្លួនការពារត្រជាក់ ៗ នៅសងខាងខ្លួនមានអ្វី? (មានស្លាបចំហេង២) ស្លាបចំហេងនេះប្រយោជន៍ដូចម្ដេច? មាន់មានជើងប៉ុន្មាន? នៅចុង ជើងមានអ្វី? ឲ្យសិស្សស្ទាបមើលខ្លួនមាន់ ហេតុម្ដេចបានជាក្ដៅខ្លាំង? ព្រោះឈាមរត់ញាប់ណាស់ មាន់កើតកូនដូចម្ដេច? ចិញ្ចឹមកូនដូចម្ដេច? លក្ខណៈសត្វចតុប្បាទនិងសត្វទ្វិបាទ សត្វស្លាបឲ្យសិស្សប្រៀបសត្វ ចតុប្បាទនិងទ្វិបាទខុសគ្នាយ៉ាងណាខ្លះ? ដូចថ្កៃនិងមាន់ ៗ ល ៗ

## ២ អំពីត្រី

វត្ថុសម្រាប់បង្រៀន ត្រីមានស្រកា ពងត្រីទឹកមួយក្អាំ ៗ

នាំសិស្សពិនិត្យមើលត្រី ៗ ខ្លួនរាងដូចម្ដេច? វែងធំកណ្ដាល ចុងដើមស្រួច ដើម្បីកុំឲ្យរាំងទឹក លើខ្លួនមានដុះអ្វី? ព្រុយដែលដុះ លើខ្នងឬក្រោមពោះត្រីហៅព្រុយអ្វី? ត្រីមានស្រកាប៉ុន្មាន? នៅឯណា

នាំសិស្សមើលត្រីហែល ព្រុយទ្រូងហើយនឹងព្រុយពោះប្រយោជន៍ដូចម្ដេច ? ( កកាយទឹកឲ្យលឿនទៅមុខ ) ព្រុយកន្ទុយប្រយោជន៍ដូចម្ដេច ? ( ប្រើជាចង្កូតប្រយោជន៍បត់ចុះបត់ឡើង ) ព្រុយខ្នងហើយនឹងព្រុយឯទៀត ( សម្រាប់ទប់ទល់ត្រីឲ្យនៅនឹងបានក្នុងទឹក ) ហេតុដូចម្ដេចបានជាស្រកីពណ៌ក្រហម ? ( ព្រោះមានឈាម ) ។ ត្រីដកដង្ហើមតាមស្រកីនេះឯង ត្រីទុកនៅលើគោករស់នៅបានឬទេ ? យកពងត្រីឲ្យសិស្សមើល ត្រីកើតកូនដូចម្ដេច ? ឲ្យសិស្សរាប់ឈ្មោះត្រីណាដែលស្គាល់ ។

អាទិត្យទី ៣.- អំពីបង្កួយ កង្កែប

អាទិត្យទី ៤.- អំពីមេអំបៅ ខ្យងនឹងបង្កង ។

---

បរិច្ឆណាដ្ឋាន

## វិធីបង្ការរោគ

អាទិត្យទី ១ អំពីកិច្ចដែលត្រូវប្រព្រឹត្តនៅវេលាដែលមានជម្ងឺធំ ៗ

រំលឹកសិស្សថាក្នុងគ្រាឥឡូវនេះមានជម្ងឺធំ ដូចជាជម្ងឺអាសន្នរោគ ជម្ងឺធំនេះរហ័សណាស់ធ្វើឲ្យអ្នកស្រុកវិនាស ហេតុនេះត្រូវឲ្យប្រយ័ត្ន

មាំមួន ឲ្យសិស្សរៀបរាប់អំពីជម្ងឺដែលឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀត អ្វីដែលនាំជម្ងឺពីម្នាក់ទៅម្នាក់ទៀត ។

កាលណាមានជម្ងឺឆ្លងនៅក្នុងផ្ទះ ត្រូវឲ្យមានសេចក្ដីប្រយ័ត្នដូចមានខាងក្រោមនេះ បំបែកអ្នកជម្ងឺឲ្យនៅដោយខ្លួន អ្នកថែជម្ងឺត្រូវមានសម្លៀកបំពាក់មួយប្រដាប់ផ្សេងសម្រាប់ ចូលទៅក្នុងបន្ទប់ជម្ងឺ ត្រូវលាងដៃនឹងទឹកសាប៊ូរួចនឹងស្រា កាលណារួចការហើយ ។

អាទិត្យទី២– កិច្ចដែលត្រូវប្រព្រឹត្តនៅវេលា ដែលមានជម្ងឺឆ្លង (ត) ការរំងាប់នឹងជៀសមេរោគវេលាដែលអ្នកមានជម្ងឺមិនទាន់ជា ត្រូវឲ្យសំអាតទីលំនៅតុទូតាំង មិនត្រូវឲ្យមានសំរាមស្អុយរលួយនៅជិតផ្ទះ សម្លៀងកុំប្រើប្រាស់របស់អ្នកជម្ងឺ ដល់អ្នកជម្ងឺជាហើយ ទីកន្លែងអ្នកជម្ងឺ ត្រូវសំអាតរំងាប់មេរោគនឹងទឹកក្រេស៊ុលបើកទ្វារបង្អួចឲ្យស្រឡះ ឲ្យពន្លឺនឹងអាកាសចូលឲ្យបានច្រើន ។ សំលៀកបំពាក់អ្នកនោះ ត្រូវយកទៅលាងស្ងោរចេញ ប្រដាប់ប្រដារដែលអ្នកចាប់កាន់ប៉ះពាល់ក៏ត្រូវធ្វើដូចនេះដែរ ។

អាទិត្យទី៣– កិច្ចដែលត្រូវប្រព្រឹត្តនៅវេលាដែលមានជម្ងឺឆ្លង (ត) ការប្រយ័ត្នខាងចំណីអាហារ សុំឲ្យគ្រូហាមប្រាមសិស្សកុំឲ្យបរិភោគផ្លែឈើខ្ចីដូចជាស្វាយខ្ចីជាដើម បន្លែស្រស់ឬផ្លែឈើណាដែលស្អុយរលួយ ទោះបន្តិចបន្តួចក៏ដោយ ។

នៅផ្ទះសម្បែងចំណីអាហារត្រូវគ្របឲ្យជិតកុំឲ្យរុយរោម អាហារទៀតត្រូវធ្វើថ្មីៗហើយចំអិនប្រាកដ គឺទុកឲ្យយូរលើភ្លើងសមបរិភោគ ។

ភេសជ្ជៈដូចជាទឹកនេះក៏ដែរ បើប្រើទឹកទន្លេឬទឹកអណ្ដូងត្រូវយកមកដាំឲ្យពុះចំនួន ២០ មីនុត ការប្រើទឹកតែក៏ជាកិច្ចមួយយ៉ាងសំខាន់ដែរ ក៏ប៉ុន្តែត្រូវឲ្យទឹកពុះយូរ ហើយមិនត្រូវចាក់ទឹកត្រជាក់លាយវេលារៀបនឹងផឹក ។

ការប្រយ័ត្នជាធំ បើកាលណាជម្ងឺឆ្លងក្នុងភូមិក្នុងស្រុកហើយ ត្រូវតែចូលទៅឲ្យគ្រូពេទ្យចាក់ថ្នាំការពារខ្លួនជាប ។

សុំគ្រូតែងសេចក្ដីសង្ខេបផងចុះ

## អាទិត្យទី៤- សាបព្រៀងជាថ្មីឡើងវិញ

---

កុមារដ្ឋាន

## វត្ថុស្វាធ្យាយន៍

## អាទិត្យទី ១– អំពីខ្យល់អាកាស

វត្ថុសម្រាប់បង្រៀន - ដុត១ កូនដបតូច ទឹក១កែវ នាំសិស្សសង្កេត បញ្ជាក់ឲ្យដឹងថាមានខ្យល់នៅគ្រប់ទីដំបន់ ។ ឲ្យសិស្សតាំង

អស់គ្នាយកសៀវភៅបក់មុខខ្លួនឯង ល្ហើយឬទេ? ពីព្រោះអ្វី? ដោយមានខ្យល់មកប៉ះនឹងមុខ ។ ហេតុដូចម្ដេចបានជាស្លឹកមែកឈើកំរើក? មកអំពីខ្យល់បក់ផាត់ ។ យើងមើលខ្យល់ឃើញឬទេ? យើងមើលពុំឃើញទេ ។ តើមានក្លិនឲ្យយើងសំគាល់បានឬទេ? ខ្យល់ឥតក្លិនទេ ។ ដូចម្ដេចបានជាយើងដឹងថាមានខ្យល់? ព្រោះយើងសំគាល់ដោយខ្យល់មាននៅកន្លែងណាខ្លះ? មានគ្រប់តម្បន់នៅជុំវិញខ្លួនយើង សូម្បីតែបន្ទោះតូចមួយក៏មានខ្យល់ដែរ ។ សូមឲ្យគ្រូយកកូនដបទៅជ្រមុជក្នុងទឹក ឲ្យសិស្សពិនិត្យមើលពពុះខ្យល់ដែលផាត់ឡើង ។

ខ្យល់មានផលប្រយោជន៍ដូចម្ដេចខ្លះ? មនុស្សសត្វ - ដើមឈើនៅក្នុងទឹកលើគោករស់បានតែដោយសារខ្យល់ ។ បើសិនណាជាគេយកកូនសត្វអ្វីមួយទៅដាក់ក្នុងកែវហើយគ្របឲ្យជិតកូនសត្វនោះនឹងស្លាប់ដោយគ្មានខ្យល់ដកដង្ហើមមនុស្សយើងដែលស្លាប់នឹងលង់ទឹកនោះក៏មានសណ្ឋានដូចគ្នាដែរ ។

## ២ អំពីខ្យល់បក់

អាទិត្យទី២ - អំពីទឹក - អំពីភ្លៀង

អាទិត្យទី៣ - អំពីព្រែក - អំពីសមុទ្រ

អាទិត្យទី៤ - រៀនសាអំពីដើមឡើងវិញ

# វិធីបង្ការរោគ

អាទិត្យទី១-២– ការសំអាតនៅទីធ្លាសាលារៀននឹងជាយៗ ។

សូមគ្រូប្រាប់សិស្សថា នៅទីធ្លាសាលារៀនត្រូវឲ្យស្អាតជានិច្ចមិនត្រូវយកក្រដាសឬកាគសំណៅឬវត្ថុអ្វីៗ ដែលនាំឲ្យមិនស្អាតទៅបាចសាចនៅទីនោះទេ ពីព្រោះទីនេះហើយគឺជាទីលំអមួយដែរ អ្នកទាំងឡាយគេដើរទៅមកគេសំគាល់ឃើញថា បើទីនោះស្អាតកន្លែងឯទៀតក៏ស្អាតដូចគ្នាដែរ ខាងក្រៅក៏ដូចខាងក្នុងបន្ទប់ដែរ ។

កន្លែងណាៗក្តី ដែលគេមើលទៅឃើញល្អគឺដោយមានសួនបុប្ផាដោយមានមន្ទីររបៀបរៀបរយ ឯទីធ្លាសាលាបើគ្មានសួនបុប្ផាគ្មានមន្ទីររៀបរយ បើជាស្អាតជានិច្ចក៏ល្អដូចទីដែលមានសួនបុប្ផាមានផ្ទះត្រឹមត្រូវនោះដែរ ។

## អាទិត្យទី៣-៤– អំពីការសំអាតបង្គន់

សូមគ្រូប្រាប់សិស្សថា បើនឹងត្រូវការទៅបង្គន់ បត់ជើងធំ ត្រូវឲ្យបំប្រុះហោង មិនត្រូវទៅខុសពីកន្លែងដែលគេសម្រាប់ឲ្យធ្វើនោះទេឬ

ជិតបង្គន់ឬខាងៗជាយ ឯបត់ជើងតូចក៏ដូច្នេះដែរ ត្រូវឲ្យត្រង់កន្លែងដែលគេបំរុងទុកឲ្យបត់ជើងនោះ ទោះបីបើជារួសរាន់យ៉ាងណាក៏ដោយ មិនត្រូវទៅធ្វើតែពាស ដូចគេឃើញតែគ្រប់សាលា ត្រង់កន្លែងដែលដោះទុក្ខសត្វមិនស្អាតសោះ បើកាលណាមិនស្អាតដូច្នេះទេ នឹងបណ្តាលឲ្យធុំក្លិនមកដល់ទីកន្លែងដែលរៀនសូត្រ នាំឲ្យធ្វើការមិនកើត ទៅជាខ្យល់ចាប់ព្រិលមុខ ដោយសេចក្តីស្មោគគ្រោកនោះ ម្យ៉ាងទៀតនឹងនាំបណ្តាលឲ្យមានជម្ងឺផង ។

---

លោកនីតិ

## សម្រាប់គ្រប់ថ្នា

### ៣ - សាលាដំបូង

សាលាដំបូងតាំងនៅទីរួមខេត្តទាំងអស់នៃកម្ពុជរដ្ឋ ។ សាលាដំបូងខេត្តកណ្តាល គឺសាលាលុឃុន នៅក្រុងភ្នំពេញខាងមុខព្រះបរមរាជវាំង ។

នៅសាលាដំបូងនីមួយៗ មានចាងហ្វាងសាលា មានព្រះរាជអាជ្ញា សុភាចារបុរស ក្រឡាបញ្ជីនឹងសមុហបញ្ជី ។ សាលាដំបូងសម្រាប់ជំនុំជំរះកាត់សេចក្តីរឿងអាជ្ញាគតិបានត្រឹមតែបទមជ្ឈិមទេ គឺធ្វើទោសដាក់គុក

ពី ៦ ថ្ងៃ ទៅ ៥ ឆ្នាំ ទាំងពិន័យជាប្រាក់តាមកំណត់ច្បាប់សម្រេចទុកមកៗ បើនៅខែត្រណាគ្មានសាលាលហុនោះ សាលាដំបូងក៏ត្រូវជំនុំជំរះបទលហុដែរ ៗ

## ៤ - សាលាក្រុមចោទ

សាលាក្រុមចោទ តាំងនៅក្រុងភ្នំពេញ សម្រាប់ពិនិត្យមើលពាក្យចោទផ្សេង ៗ ដែលគូក្ដីមិនសុខចិត្តនឹងការជំនុំជំរះ នៅសាលាដំបូងនានា ៗ

លុះបានពិចារណាមើលរឿងទាំងនោះឃើញត្រឹមត្រូវហើយ ឬមួយនៅចន្លោះកិច្ចម្យ៉ាង ៗ ពុំបានពោលសេចក្ដីបរិបូណ៌ក៏ធ្វើពត៌មានតាមហេតុពិនិត្យនោះជូនទៅសាលាឧទ្ធរណ៍ជំនុំជំរះ ៗ

សាលាក្រុមចោទនេះជាសាលាជំនួយនៃសាលាឧទ្ធរណ៍

## ៥ - សាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍មានតែមួយទេ តាំងនៅក្រុងភ្នំពេញសម្រាប់ពិភាក្សាកាត់សេចក្ដីសាជាថ្មី ដែលគូក្ដីមិនសុខចិត្តនឹងសាលាលហុ សាលាដំបូងដែលជំនុំជំរះកាត់សេចក្ដីបើកផ្លូវឧទ្ធរណ៍ អំពីលហុក្ដី មជ្ឈិមក្ដី ៗ

## ៦ - សាលាឧក្រិដ្ឋ

សាលាឧក្រិដ្ឋសម្រាប់ជំនុំជំរះទោសធ្ងន់ដែលចូលជាបទឧក្រិដ្ឋ តាំងពីទោស ៦ ឆ្នាំទៅដល់ទោសអស់ជីវិត ឬត្រូវពិឃាតជីវិតបង់ ៗ

បើមិនសុខចិត្តនឹងសាលក្រម សាលាឧក្រិដ្ឋទេ ត្រូវប្តឹងទៅសាលាវិនិច្ឆ័យជាសម្រេច ។

## ៣ - សាលាវិនិច្ឆ័យ

សាលាវិនិច្ឆ័យក៏មានតែមួយ ដូចជាសាលាឧទ្ធរណ៍នឹងឧក្រិដ្ឋដែរ តាំងនៅក្រុងភ្នំពេញ ជាសាលាធំបំផុតសម្រាប់ពិនិត្យរឿងហេតុនឹងជំនុំជំរះសាឡើងវិញ ក្តីណាគូវិវាទប្តឹងសាទុក្ខមិនសុខចិត្តនឹងសាលក្រម សាលាលហុ, សាលាដំបូង, សាលាឧក្រិដ្ឋ, សាលាឧទ្ធរណ៍, បើពិភាក្សាទៅឃើញថា កាត់ខុសនឹងច្បាប់ក៏ជំនុំជំរះសាជាថ្មីឡើងវិញ ឲ្យបានត្រឹមត្រូវ បើឃើញថាជំនុំជំរះបានសុចរិតត្រឹមត្រូវហើយនោះ ត្រូវបដិសេធពាក្យបណ្តឹងសាទុកចេញ ។

សាលាជំនុំជំរះក្តីក្នុងកម្ពុជរដ្ឋផុតអស់ត្រឹមសាលាវិនិច្ឆ័យនេះហើយ ។

## មេសូត្ររត់មាត់

(សម្រាប់គ្រប់ថ្នាក់)

## ១- ត្រូវជួយធ្វើការឪពុកម្តាយអ្នក

សិស្សអើយអ្នកត្រូវ គិតគ្នេរឲ្យជ្រៅ នូវកិច្ចសព្វគ្រប់ ឪពុកម្តាយអ្នក
ធ្វើការឥតឈប់ ពីព្រឹកទល់យប់ ទើបឈប់សម្រាក ។ គួរអ្នករិះគិត

ឲ្យបានឃើញពិត ថាគាត់លំបាក ព្រោះស្រឡាញ់អ្នក មេត្តាគ្មាន-ស្រាក ថ្ងៃឈប់សម្រាក ជួយធ្វើកុំខ្ជិល ។

## ២- គ្មានអ្វីឲ្យសប្បាយជាជាងនៅជួបជុំក្រុមញាតិ

ពេលព្រឹកយាត្រា ឪទៅចំការ មាតានៅផ្ទះ កូនប្រុសទៅរៀន កូនស្រីដេរប៉ះ ល្ងាចទើបត្រូវរះ មកផ្ទះគ្រប់គ្នា ។ លុះមកដល់ទី ម្ដាយនិងកូនស្រី រៀបចំអាហារ អង្គុយជួបជុំ ព័ទ្ធតុភោជនា ចាប់ចានកត្តា ក្ដៅៗឈ្ងុយឆ្ងាញ់ ។ ការដែលជុំគ្នា ទោះបីអាហារ ពុំគាប់ស្រឡាញ់ ក៏ប្រែទៅជា អាហារយ៉ាងឆ្ងាញ់ បរិភោគឆ្អែតពេញ បរិបូណ៌គ្រប់គ្នា ។

### ពាក្យពន្យល់.-

ភោជនា = វត្ថុសម្រាប់បរិភោគ ។

កត្តា = បាយ, អាហារ

## ៣- សំបុត្រកំណើត

នៃជនទាំងឡាយ ជាឪពុកម្ដាយ ត្រូវកុំប្រហែស កូនកើតបីថ្ងៃ គិតលៃជួបចុះ បញ្ជីជាតិនេះ កុំភ្លេចឲ្យសោះ ។ រកសាក្សីពីរ ទៅកាន់មន្ទីរ មន្ត្រីចុះឈ្មោះ ចុះជាតិកំណើត នៃទារកនោះ តែបើកើតស្មោះ មន្ទីរពេទ្យទេ ។ មិនបាច់សាក្សី អាចប្ដឹងមន្ត្រី

ហើយតែគិតគ្នេរ ចំឡងមួយច្បាប់ ឲ្យមានដូចគេ ទុកដូចជាគេដ៏ ឲ្យកូនទៅរៀន ។

ពាក្យពន្យល់- ទារក = ( ម.ជ រក់ ) កូនក្មេងទើបនឹងកើត ពី ១ ថ្ងៃដល់ទៅ ១ ឆ្នាំ ។

## ៤- ត្រូវកុំនិយាយកុហក

ឪពុកម្ដាយមិននៅ　　ចៅសុខ ,.... សៅប្រឡែងគ្នា
ស្រាប់តែឈ្លូសជើងពារ　　ប៉ះកញ្ចក់នៃម្ដាយបែក ។
ចៅសុខគិតភ័យខ្លាំង　　ស្រឡាំងកាំងក្រឡេកភ្នែក
គិតថាកញ្ចក់បែក　　មុខជាអញត្រូវរំពាត់ ។
ចៅសៅប្រាប់បងថា　　យើងគិតគ្នាកុហកគាត់
ថាឆ្មាបោលមកក្ងាត់　　ប៉ះកញ្ចក់បែកខ្ចាយទៅ ។
សៅជាពុំគួរទេ　　បង្ខំបគេនាំហ្នងសៅ
គ្រូអញប្រៀនប្រដៅ　　ថាមិនត្រូវពោលកុហក ។
លុះដល់ម៉ែឪមក　　ចៅសុខប្រាប់ពុំដំអក់
ចិត្តគាត់ឥតក្នាញ់ខ្នក់　　គិតថាកូននិយាយត្រង់ ។
គ្រាន់តែហាមប្រាមថា　　ក្រោយកុំបាលេងឲ្យលង់
សិស្សអើយប្ដូរតម្រង់　　ពោលឲ្យត្រង់ដូចចៅសុខ ។

ពាក្យពន្យល់.- ពោល = និយាយ, ស្តី, ថា ។ ដំអក់ = អែអង់, អេវង់, ចំអៀក ។ ខ្នាញ់ខ្នក់ = មិនស្រួលចិត្តដោយ មានហេតុអ្វីផ្សេង ៗ ជាទីពាស់ចិត្ត ។ បា = អ្នក, ពាក្យសម្រាប់ហៅកូនប្រុស ។

## ៥- កុំអាងកម្លាំងឬអំណាចរបស់ខ្លួន

មនុស្សជាតិសព្វថ្ងៃនេះ
ខ្លះមានទ្រព្យបវរ
អ្នកចេះឬអ្នកមាន
បើឃើញគ្នាលំបាក
កុំអាងមានឬចេះ
ដូចជាបណ្ឌិតបង
ក្របីលើភ្លឺស្រែ
ឮសូរស្រមោចហៅ
សួរទៅពួកស្រមោច
បើសិនលោកយាត្រា
ស្លាប់អស់កូនចៅខ្ញុំ

មានល្ងង់–ចេះមានកាលក្រ
ខ្លះត្រូវរស់លំបាក ។
កុំបំពានអ្នកតោកយាក
គួរអាសូរមេត្តាផង ។
ប្រាជ្ញដៀលតិះថាខុសគ្គង
និទានមានតទៅ ។
កំពុងតែដើរស៊ីស្មៅ
កុំទុបនៅក្រែងមានការណ៍ ។
ស្រមោចឆ្លើយសូមមេត្តា
ទៅមុខទៀតជាន់សំបុក ។
គាណិតកុំដើរទៅមុខ

គ្រប់ទឹកភ័យក្តុក
ដោយអាណិតចិត្តស្រមោច ៗ
គ្រប់ចិត្តបរិសុទ្ធ
ពួកសត្វផុតពីហិនហោច
អ្នកគ្រដួបស្រមោច ,
ឯអ្នកមានដួបគ្រប់ ៗ

## ពាក្យពន្យល់ៈ-

បវរ = (ម.ថ. វ៉) ប្រសើរ, លើសលែង ៗ
ត្រដរ = ខំប្រឹង, ខំស៊ុះឡើង ៗ គោកយាក = ដែលទ័លក្រ ៗ បណ្ឌិត = អ្នកប្រាជ្ញ ៗ
ការណ៍ (ម.ថ. កា) ហេតុ, ដំណើរ ៗ
បរិសុទ្ធ = (ម.ថ.បរិសុត) ដែលស្អាត, ឥត សៅហ្មង ៗ

រោងពុម្ពខ្មែរ